# អត្ថបទព្រះធម៌

## ភាគ៥

### សំរាប់មនុស្សគ្រប់វ័យ



ដោយ

ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា**

ព.ស.២៥៥៣ គ.ស.២០០៩

www.hoksavann.org

**ចែកជាធម្មទាន**

# ប្រវត្តិរូបសង្ខេប
# ព្រះតេជព្រះគុណបណ្ឌិត ហុក សាវណ្ណា

ៜៜៜ❁ៜៜៜ

ប្រសូត ថ្ងៃ១០មីនា១៩៤០ នៅឃុំព្រៃកប្បាស ស្រុកព្រៃ-កប្បាស ខេត្តតាកែវ ប្រទេសកម្ពុជា, ព្រះតេជព្រះគុណបណ្ឌិត **ហុក សាវណ្ណា** ជាបុត្រទី៣ក្នុងបណ្ដាបុត្រទាំង៥នាក់ បិតានាម **ហុក ហៃ** មាតានាម **សុខ យឹម**។ ព្រះជន្ម១៥ឆ្នាំ បានបួសជាសាមណេរ លុះព្រះជន្ម២១ឆ្នាំ បានបំពេញឧបសម្បទាជាភិក្ខុ។ កាលប្រព្រឹត្តការណ៍ឆ្នាំ១៩៧៥ ព្រះអង្គបានភៀសខ្លួនទៅប្រទេសថៃ បន្ទាប់មកបានទៅរស់នៅទីក្រុងម៉ុងរេ-អាល់ ប្រទេសកាណាដា នៅថ្ងៃ២៣មេសា១៩៨១។

កាលពីកុមារភាព ព្រះអង្គបានសិក្សាអក្សរសាស្ត្រជាតិចប់បឋមសិក្សា។ ពេលចូលកាន់ផ្នួស ព្រះអង្គបានសិក្សាធម្មវិន័យទាំង៣ថ្នាក់ត្រីទោឯក បានសិក្សានៅពុទ្ធិកសិក្សា ជាប់ពុទ្ធិក-បឋមសិក្សា ពុទ្ធិកមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ និងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ។ ឆ្លៀតទៅរៀនអក្សរសាស្ត្រនិងមនុស្សសាស្ត្រនៅសាកលវិទ្យាល័យភ្នំពេញ។ ក្រៅពីសិក្សាគន្ថធុរៈ ព្រះអង្គបានប្រតិបត្តិវិបស្សនាធុរៈអស់ជាច្រើន

ឆ្នាំ។ នៅបរទេស ព្រះអង្គបានសិក្សាបន្តជាប់អនុបណ្ឌិត (Master´s degree) ទីបំផុត ជាប់បណ្ឌិតទស្សនាវិជ្ជាផ្នែកព្រះពុទ្ធសាសនា (Doctor of Philosophy on Buddhism) នៅសាកលវិទ្យាល័យញូដែល្លី នៃប្រទេសឥណ្ឌា នៅថ្ងៃ២៨កុម្ភៈ ២០០៤។

នៅក្នុងប្រទេសក៏ដូចជានៅក្រៅប្រទេស ព្រះអង្គបានជួយសង្គមខ្មែរយ៉ាងច្រើនផ្នែកបញ្ញាស្មារតី ដោយវិធីទេសនាពន្យល់តាមមាគ៌ាព្រះពុទ្ធសាសនា។

# មាតិកាអត្ថបទ


| | |
|---|---|
| ១. មនុស្សជាកំណើតប្រសើរ | ១ |
| ២. ពុទ្ធភាសិតថា «ខ្លួនទីពឹងខ្លួន» | ៦ |
| ៣. ធម៌តែងរក្សាអ្នកប្រព្រឹត្តធម៌ | ១១ |
| ៤. ពាក្យខ្មែរថា ចាញ់បានជាព្រះឈ្នះបានជាមារ | ១៥ |
| ៥. ការមិនមានរោគ ជាលាភដ៏ប្រសើរ | ១៨ |
| ៦. ធម្មរសឈ្នះអស់រសទាំងពួង | ២២ |
| ៧. សមភាពផ្លូវលោកនិងផ្លូវធម៌ | ២៥ |
| ៨. វិជ្ជាផ្លូវលោកនិងផ្លូវធម៌ | ២៩ |
| ៩. កម្មផលក្នុងព្រះពុទ្ធសាសនា | ៣៣ |
| ១០. ព្រះពុទ្ធដឹកនាំអ្នកប្រតិបត្តិឲ្យចេញចាកទុក្ខ | ៣៨ |
| ១១. គុណមាតាបិតាប្រៀបមកគុណព្រះពុទ្ធ | ៤១ |
| ១២. ករុណាត្រូវមានបញ្ញា | ៤៦ |
| ១៣. សីល៥របស់ព្រះពុទ្ធសាសនា | ៥៣ |
| ១៤. ចរិយា៣យ៉ាងរបស់ព្រះពុទ្ធ | ៥៧ |
| ១៥. អធិបតេយ្យធម៌៣យ៉ាង | ៦២ |
| ១៦. វាសនាបន្ទាប់ពីសេចក្តីស្លាប់ | ៦៨ |
| ១៧. ទីស្ងាត់ពុំមានក្នុងលោក | ៧៤ |
| ១៨. ការចូលព្រះវស្សារបស់ភិក្ខុសង្ឃ | ៧៨ |
| ១៩. បុណ្យអុំទូក សំពះព្រះខែ បណ្តែតប្រទីប | ៨២ |

# ១- មនុស្សជាកំណើតប្រសើរ

ពាក្យថា **មនុស្ស** តាមសព្ទបាលីប្រែថា អ្នកដឹងខុសត្រូវ មកពីវិគ្គហៈថា **ការណាការណំ មនតិ ជានាតីតិ មនុស្សោ** (*សត្តវិសេសោ*) ប្រែថា (សត្វពិសេស) អ្នកដឹងហេតុគួរនិងហេតុមិនគួរ ហៅថា **មនុស្ស**។ បានសេចក្តីថា បញ្ញត្តិសព្ទថា មនុស្ស សំដៅយកសត្វពិសេសមួយពួក ដែលមានការរីកចំរើនខាងគំនិតបញ្ញា គឺមានធម្មសញ្ញាប្រសើរជាងសត្វតិរច្ឆាន។ សត្វតិរច្ឆានទោះបីរស់នៅច្រើនតំណតពីមេបាវាក៏ដោយ ក៏ពុំអាចរីកចំរើនខាងគំនិតបញ្ញាឡើយ ដូចជាសត្វចាបសត្វកណ្តៀរ ធ្វើសំបុកធ្វើដំបូក មេបាវាធ្វើយ៉ាងណា កូនចៅវាក៏នៅតែធ្វើយ៉ាងនោះ វាពុំមានគំនិតបញ្ញាច្នៃឲ្យប្រសើរជាងនោះទៀតឡើយ គឺវារស់នៅតាមសភាវគតិ។ ចំណែក មនុស្សអាចរីកចំរើនលូតលាស់ខាងចំណេះចេះដឹងគ្រប់យ៉ាងនិងចរិយាសម្បត្តិថ្លៃថ្នូរ បើគេបានសិក្សាអប់រំតាមផ្លូវល្អ។ មនុស្សមានអាយុវែងជាងសត្វតិរច្ឆានភាគច្រើន ហើយមានជីវិតប្រសើរ ព្រោះមនុស្សអាចសាងសុភមង្គលឲ្យដល់ខ្លួន។ តាមរូបវិទ្យា ខួរក្បាលមនុស្សមានសក្តានុភាពអាចបង្កើតសតិបញ្ញាស្មារតីបានយ៉ាងល្អប្រ

សើរ។ សង្គមមនុស្សតាំងពីចាប់ផ្ដើមប្រវត្តិសាស្ត្ររហូតមកដល់បច្ចុប្បន្ននេះ បានរីកចំរើនគ្រប់វិស័យទាំងផ្នែកសម្ភារៈទាំងផ្នែកសតិបញ្ញានិងផ្នែកសីលធម៌។

ព្រះពុទ្ធសំដែងថា ការកើតមកជាមនុស្សជាការក្រ ព្រោះបើប្រៀបធៀបជាមួយសត្វតិរច្ឆាន ចំនួនមនុស្សនៅតែមានចំនួនតិចជាងសត្វតិរច្ឆាន។ ចំពោះមនុស្សទោះបីកើតមកពីធាតុ៤ដូចគ្នា មានអាយតនៈដូចគ្នាក៏ដោយ ប៉ុន្តែមានទម្រង់រូបរាងកាយនិងចិត្តគំនិតផ្សេងៗគ្នា ទៅតាមឧបនិស្ស័យនិងការអប់រំរបស់ខ្លួន។ មនុស្សគ្រប់ជនជាតិមានចិត្តគំនិតមួយដូចគ្នា គឺចង់បានសេចក្ដីសុខ។ ត្រង់នេះហើយបានជាព្រះពុទ្ធសំដែង កុំឲ្យមនុស្សបៀតបៀនគ្នា ព្រោះមនុស្សសុទ្ធតែស្រឡាញ់សេចក្ដីសុខដូចគ្នាទាំងអស់។ បើមនុស្សបៀតបៀនគេ នឹងត្រូវទទួលផលជាទុក្ខតបវិញ។ ព្រះពុទ្ធបានចែកមនុស្សជា៤ប្រភេទទៅតាមអំពើដែលគេបានធ្វើ គឺពុំមែនចែកទៅតាមរូបរាងកាយទ្រព្យសម្បត្តិ ជាតិត្រកូលយកសក្តិទេ។ មនុស្ស៤ប្រភេទនោះគឺ **មនុស្សោ** រូបរាងកាយជាមនុស្ស អំពើប្រព្រឹត្តប្រកបដោយធម៌របស់មនុស្សគឺមនុស្សធម៌ ពុំបៀតបៀនអ្នកដទៃជាពិសេសជាអ្នកមានសីល៥។ **មនុស្សបេតោ** រូបរាងកាយជាមនុស្ស ប៉ុន្តែ

អំពើប្រព្រឹត្តធ្វើឲ្យអ្នកដទៃខាតបង់ទ្រព្យសម្បត្តិ កំណាញ់ពុំធ្វើទានជួយសង្គ្រោះអ្នកដទៃដែលក្រីក្រជាងខ្លួនជាដើម ស្លាប់ទៅកើតជាប្រេត។ **មនុស្សនេរយិកោ** រូបរាងកាយជាមនុស្ស ប៉ុន្តែអំពើប្រព្រឹត្តកាប់សម្លាប់អ្នកដទៃជាដើម មនុស្សប្រភេទនេះស្លាប់ទៅធ្លាក់នរក។ **មនុស្សតិរច្ឆានោ** រូបរាងកាយជាមនុស្ស អំពើប្រព្រឹត្តពុំដឹងគុណមាតាបិតាជាដើម មនុស្សប្រភេទនេះស្លាប់ទៅកើតជាសត្វតិរច្ឆាន។ មានមនុស្សមួយប្រភេទទៀតហៅថា**មនុស្សទេវោ** ប្រែថា មនុស្សទេវតា គឺជាអ្នកមាន **ហិរិ ឱត្តប្បៈ** ខ្មើមបាបខ្លាចបាបពុំហ៊ានប្រព្រឹត្តធ្វើ គឺជាអ្នកប្រព្រឹត្តតាមទេវធម៌។ ពិសេសមានមនុស្សដ៏ខ្ពស់ខ្ពង់មួយប្រភេទទៀត គឺ **វិសុទ្ធិមនុស្ស** ឬ **វិសុទ្ធិទេព** ប្រែថា មនុស្សបរិសុទ្ធឬទេវតាបរិសុទ្ធបានដល់ព្រះអរហន្តមានព្រះពុទ្ធជាដើម ព្រោះលោកកំចាត់បង់បាបអស់ហើយ។

ព្រះសម្ពុទ្ធវិនិច្ឆ័យមនុស្សខ្ពស់ខ្ពង់និងថោកទាបដោយសារអំពើរបស់គេ។ ថ្ងៃមួយ ព្រះសម្ពុទ្ធបាននិមន្តទៅបិណ្ឌបាត្រ ព្រះអង្គបានឈប់នៅមុខផ្ទះព្រាហ្មណ៍ម្នាក់ ព្រាហ្មណ៍បានឃើញហើយ និយាយទៅកាន់ព្រះពុទ្ធដោយពាក្យពុំសមរម្យថា នែសមណៈតូចទាប នែសមណៈថោកទាប យើងមិនដាក់បាត្រទេ

សូមនិមន្តទៅទៀតចុះ។ ពេលនោះ ព្រះសម្ពុទ្ធត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកឯងដឹងបុគ្គលថោកទាប និងធម៌ដែលធ្វើឲ្យបុគ្គលថោកទាបហើយឬនៅ? ព្រាហ្មណ៍ឆ្លើយតបថា ខ្ញុំព្រះអង្គពុំទាន់ដឹងទេ។ ព្រះអង្គត្រាស់ថា ម្នាលព្រាហ្មណ៍ ទំនាប និងកំពស់របស់មនុស្សពុំមែនស្ថិតនៅលើរូបរាងកាយជាតិត្រកូលទ្រព្យសម្បត្តិយសស័ក្តិទេ តែត្រូវស្ថិតនៅលើកម្ម គឺអំពើដែលគេបានប្រព្រឹត្ត។បុគ្គលណាប្រព្រឹត្តល្អដោយកាយវាចានិងចិត្ត បុគ្គលនោះជាបុគ្គលខ្ពស់ខ្ពង់។ បុគ្គលណាប្រព្រឹត្តអាក្រក់ដោយកាយវាចានិងចិត្ត បុគ្គលនោះជាបុគ្គលថោកទាប។ ពេលនោះ ព្រាហ្មណ៍ក៏កើតចិត្តជ្រះថ្លាចំពោះព្រះអង្គដោយបានស្តាប់ពាក្យពិតនេះ។ ពុទ្ធសាសនាពោលថា មនុស្សនឹងមានវាសនាអនាគតទៅជាយ៉ាងណានោះ អាស្រ័យឧបនិស្ស័យពីមុនមកផង អាស្រ័យកម្មផលដែលខ្លួនប្រព្រឹត្តក្នុងបច្ចុប្បន្នផង។មនុស្សតែងមានគុណសម្បត្តិផងគុណវិបត្តិផង ចំពោះរឿងនេះ ព្រះពុទ្ធសំដែងដាស់តឿនថា បើរៀនហាត់លះអំពីអាក្រក់ដែលជាគុណវិបត្តិឲ្យថយចុះរាល់ថ្ងៃ ហើយរៀនហាត់បណ្តុះអំពើល្អដែលជាគុណសម្បត្តិឲ្យបានច្រើនរាល់ថ្ងៃ នោះគុណសម្បត្តិនឹងកើតមានកាន់តែច្រើនឡើង មនុស្សនោះលោកហៅថា

**កល្យាណមុជ្ជុន** រស់នៅមានប្រយោជន៍ដល់សង្គមមនុស្ស បើស្លាប់ទៅ គេនៅតែសោកស្តាយ។

ឲ្យឲ្យឲ្យឲ្យឲ្យ

# ២- ពុទ្ធភាសិតថា «ខ្លួនទីពឹងខ្លួន»

ពុទ្ធភាសិតថា **អត្តា ហិ អត្តនោ នាថោ** ប្រែថា ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន។ ពាក្យថា ខ្លួនជាទីពឹងរបស់ខ្លួន ពុំមែនព្រះពុទ្ធទទួលស្គាល់ថាមានអត្តា ដូចជាសាសនាព្រាហ្មណ៍ដែលយល់ថា នៅក្នុងខ្លួនមនុស្សសត្វ មានអត្តាគឺខ្លួនឬព្រលឹងវិញ្ញាណពុំចេះរលត់នោះឡើយ។ ព្រះអង្គមានញាណឃើញតាមសេចក្ដីពិតថា ខ្លួនមនុស្សសត្វដែលប្រកបដោយខន្ធ៥មានរូបខន្ធជាដើមនេះ ជាអនត្តាពុំមែនខ្លួន ព្រោះជាសង្ខារប្រព្រឹត្តទៅដោយខ្លួនវា តាមច្បាប់ធម្មជាតិមិនស្ដាប់បង្គាប់។ ចំណែកអត្តាក្នុងពុទ្ធភាសិនេះ សំដៅយកខ្លួនដែលផ្សេងពីអ្នកដទៃហើយសកម្មភាពល្អគ្រប់យ៉ាងត្រូវធ្វើដោយខ្លួនឯង ដូចពុទ្ធភាសិតមួយបទទៀតពោលថា សេចក្ដីបរិសុទ្ធក្តី ពុំបរិសុទ្ធក្ដីត្រូវកើតចេញមកពីខ្លួនឯង អ្នកដទៃពុំអាចញ៉ាំងអ្នកដទៃឲ្យបរិសុទ្ធនិងមិនបរិសុទ្ធបានឡើយ។ ពាក្យថា ខ្លួនជាទីពឹងរបស់ខ្លួននេះដកចេញពីពុទ្ធភាសិតទាំងមូលថា ខ្លួនហ្នឹងឯងជាទីពឹងរបស់ខ្លួន អ្នកដទៃនឹងជាទីពឹងដូចម្ដេចបាន បើបុគ្គលមានខ្លួនទូន្មានល្អហើយ រមែងបាននូវទីពឹងដែលគេបានដោយកម្រ។ ត្រង់នេះ

មានន័យដ៏ជ្រៅថា អ្នកដែលមានខ្លួនទូន្មានរហូតបានសម្រេចជាព្រះអរហន្ត ជាថ្នាក់ខ្ពស់របស់ព្រះពុទ្ធសាសនា ក៏ដោយសារការប្រតិបត្តិតាមធម៌ គឺ **សីល សមាធិ បញ្ញា** ដោយខ្លួនឯង។ ពុទ្ធបរិស័ទតែងសូត្រថា យក **ព្រះពុទ្ធ ព្រះធម៌** និង **ព្រះសង្ឃ** ជាទីពឹងទីរលឹកស្មើដោយជីវិតនោះ មានន័យថា ជឿការត្រាស់ដឹងរបស់ព្រះអង្គ ជឿព្រះធម៌ជាមាគ៌ាចេញចាកទុក្ខ ជឿព្រះសង្ឃជាអ្នកប្រតិបត្តិដ៏ត្រឹមត្រូវតាមមគ្គប្រកបដោយអង្គ៨។ បន្ទាប់ពីមានជំនឿដូច្នេះហើយ ក៏ខំប្រតិបត្តិតាមព្រះធម៌ដែលព្រះអង្គសំដែងប្រាប់ ពុំមែនពឹងព្រះពុទ្ធឲ្យព្រះអង្គជួយឲ្យសម្រេចមគ្គផលថ្នាក់ណាមួយឡើយ។ ព្រះអង្គគ្រាន់តែបង្ហាញធម៌ប្រតិបត្តិប៉ុណ្ណោះ បើចង់បានសម្រេចមគ្គផលថ្នាក់ណាមួយត្រូវប្រតិបត្តិដោយខ្លួនឯង។ មួយទៀត ដូចគ្រូបង្រៀននិងសាស្ត្រាចារ្យមានភារកិច្ចត្រឹមតែពន្យល់ណែនាំសិស្សនិងនិស្សិតតាមមុខវិជ្ជាបង្រៀន ត្រូវសិស្សនិងនិស្សិតខំប្រឹងប្រែងស្តាប់លោកពន្យល់និងធ្វើកិច្ចការដែលលោកដាក់ឲ្យ ទើបអ្នកសិក្សាមានការចេះដឹង ពុំមែនគ្រូជួយឲ្យចេះដោយសិស្សខ្លួនឯងពុំបានប្រឹងប្រែងសិក្សារៀនសូត្រនោះឡើយ។

ពិតមែនតែមនុស្សក្នុងលោករស់នៅតែងតែពឹងពាក់គ្នាទៅវិញទៅមក ដូចម្ដាយឪពុកកូនចៅប្ដីប្រពន្ធគ្រូនិងសិស្សអ្នកដឹកនាំនិងប្រជាពលរដ្ឋ ព្រះសង្ឃនិងគ្រហស្ថ ប្រទេសនីមួយៗនិងអង្គការសហប្រជាជាតិជាដើម តែងពឹងពាក់គ្នាតែងជួយឧបត្ថម្ភគ្នា ប៉ុន្តែជាការជួយម្ដងម្កាល ពុំមានជួយជានិច្ចទេឡើយ ជាការជួយខាងក្រៅ ហើយអ្នកដែលគេអាចជួយ លុះត្រាតែមានលក្ខណៈគួរគេជួយ ឯការជួយនោះគ្រាន់តែជាការជួយឧបត្ថម្ភប៉ុណ្ណោះ ត្រូវតែខ្លួនឯងជួយខ្លួនឯង។ សុភាសិតរបស់ពួកបស្ចឹមប្រទេសក៏មាននិយាយថា **ដើម្បីឲ្យទេវតាជួយអ្នក អ្នកត្រូវជួយខ្លួនអ្នកជាមុនសិន។**

ពាហិរសាសនា គឺសាសនាខាងក្រៅពីព្រះពុទ្ធសាសនានិយាយថា ព្រះអាទិទេពមានអំណាចឲ្យសុខឲ្យទុក្ខឲ្យឡើងស្ថានសួគ៌ឲ្យចុះនរកដល់មនុស្សសត្វ។ បើមនុស្សសត្វជឿព្រះអង្គធ្វើឲ្យព្រះអង្គសព្វព្រះទ័យព្រះអង្គឲ្យកើតក្នុងស្ថានសួគ៌ បើមិនជឿព្រះអង្គធ្វើឲ្យព្រះអង្គខ្ញាល់ព្រះអង្គនឹងឲ្យធ្លាក់នរក។ សុខទុក្ខចំរើនវិនាសនរកស្ថានសួគ៌កើតចេញពីព្រះអាទិទេព ពុំមែនកើតឡើងពីអំពើល្អអាក្រក់របស់មនុស្សសត្វកសាងដោយខ្លួនឯងខ្លួនទីពឹងខ្លួនដូចព្រះពុទ្ធសាសនាពោលទេឡើយ។ ទស្សនៈ

របស់ពាហិរសាសនានេះ ពុំមែនភ័ស្តុតាងណាបញ្ជាក់ថាជាការពិតឡើយ។ ចំណែកព្រះពុទ្ធសាសនាវិញ ដូចបានពោលមកហើយ អ្វីទាំងអស់កើតពីកម្មផលឬហេតុផលតាមសភាពខ្លួនវា មានលក្ខណៈជាសាកលតាមច្បាប់ធម្មជាតិ ដែលគេអាចពិសោធឃើញការពិតបានក្នុងជីវិតបច្ចុប្បន្ន។ ក្រុមអ្នកស្រាវជ្រាវវិទ្យាសាស្ត្របានទទួលស្គាល់តម្លៃរបស់ព្រះពុទ្ធសាសនាថា មានហេតុផលពិតស្របតាមលក្ខណៈវិទ្យាសាស្ត្រដែលខ្លួនបានពិសោធឃើញ ដូចមនុស្សឈឺ កើតឡើងពីហេតុគឺមេរោគតាមប្រភេទរបស់ជម្ងឺជាដើម។ ដរាបណាវិទ្យាសាស្ត្រចេះតែលូតលាស់ ដរាបនោះព្រះពុទ្ធសាសនាចេះតែបង្ហាញការពិតកាន់តែច្បាស់លាស់ឡើង។ គេសង្កេតឃើញថា ចំនួនអ្នកកាន់ពាហិរសាសនានៅបស្ចឹមប្រទេស គឺនៅលោកខាងលិចដូចជាសហរដ្ឋអាមេរិកកាណាដា បារាំងជាដើមបានត្រូវថយចុះ ហើយចំនួនអ្នកកាន់ព្រះពុទ្ធសាសនាកាន់តែចំរើនឡើង។ ដូច្នេះហើយបានជាបេសកជនរបស់ពាហិរសាសនាបានងាកទៅបញ្ចុះបញ្ចូលអូសទាញប្រជាជននៅប្រទេសនៃទ្វីបអាស៊ីដែលកំពុងមានវិបត្តិដូចជាប្រទេសកម្ពុជាជាដើម ដោយមធ្យោបាយចែកអំណោយនិងបង្រៀនភាសាអង់គ្លេសជានុយបញ្ឆោតឲ្យជឿសាសនា

របស់ខ្លួន ព្រោះពុំអាចផ្សាយនៅក្នុងប្រទេសលោកខាងលិចឲ្យគេជឿបានទៀតឡើយ។ សម័យបារាំងធ្វើអាណានិគមលើប្រទេសកម្ពុជា បារាំងគ្រវីលក្បាលដោយពោលថា ខ្មែរក្បាលរឹងណាស់មិនងាយអូសទាញឲ្យជឿសាសនាដទៃទៀត ក្រៅពីព្រះពុទ្ធសាសនាឡើយ។

ᨀᨀᨀᨀᨀ

# ៣- ធម៌តែងរក្សាអ្នកប្រព្រឹត្តធម៌

ពាក្យពុទ្ធភាសិតថា **ធម្មោ ហវេ រក្ខតិ ធម្មចារី ធម្មោ សុចិណ្ណោ សុខមាវហាតិ** ប្រែថា ធម៌ហ្នឹងឯង តែងរក្សាអ្នកប្រព្រឹត្តធម៌ ធម៌ដែលបុគ្គលសន្សំល្អហើយ តែងនាំមកនូវសេចក្តីសុខ។ ពាក្យថា ធម៌ក្នុងពុទ្ធភាសិតនេះ សំដៅយកកុសលធម៌ គឺអំពើល្អដែលប្រព្រឹត្តទៅតាមកាយវាចានិងចិត្ត។ ការប្រព្រឹត្តល្អតាមផ្លូវកាយមានបីគឺការមិនសម្លាប់មនុស្សសត្វ មិនលួចទ្រព្យសម្បត្តិអ្នកដទៃ ការមិនរំលោភលើប្រពន្ធកូននិងប្តីជនដទៃតាមផ្លូវភេទ។ ការនិយាយល្អតាមផ្លូវវាចាមានបួនគឺការមិននិយាយកុហក មិនពោលពាក្យញុះញង់បំបែកបំបាក់ មិនពោលពាក្យតិះដៀលជេរប្រទេច មិនពោលពាក្យឥតប្រយោជន៍។ គំនិតល្អតាមផ្លូវចិត្តមានបីគឺ មិនមានគំនិតព្យាបាទ មិនមានគំនិតចង់បានទ្រព្យសម្បត្តិអ្នកដទៃ មានគំនិតយល់ត្រូវតាមសភាពពិត។ ការប្រព្រឹត្តល្អដោយកាយវាចានិងចិត្តនេះហៅថា កុសលកម្មបថ១០។ អ្នករស់នៅតាមធម៌ជាប្រក្រតី គឺអ្នកដែលប្រព្រឹត្តធ្វើអំពើគ្រប់យ៉ាងមិនឲ្យប៉ះពាល់ដល់សេចក្តីសុខរបស់អ្នកដទៃ ជាអ្នករស់នៅក្នុងសេចក្តីសុខស្ងប់ហើយតែងមានចិត្តចង់ជួយ

ដោះទុក្ខអ្នកដទៃផង។ អ្នករស់នៅក្នុងធម៌តែងមានចិត្តពុំលំអៀងដោយស្រឡាញ់ដោយស្អប់ដោយភ័យខ្លាចនិងដោយល្ងង់ឡើយ។ អ្នកមានចិត្តធម៌តែងធ្វើឲ្យអ្នករស់នៅជាមួយនិងអ្នកដែលមកប្រាស្រ័យទាក់ទងបានទទួលសេចក្តីសុខ។ អ្នកមានចិត្តធម៌តែងទទួលការស្រឡាញ់រាប់អានពីមនុស្សទូទៅ មានកេរ្តិ៍ឈ្មោះល្អ មានសេចក្តីក្លាហានក្នុងទីប្រជុំ ព្រោះលោកពុំមានកំហុសអំពីរឿងអ្វីមួយ។ ប្រជាប្រិយភាពបែបនេះកើតឡើងដោយសារគុណធម៌របស់លោកអ្នកមានធម៌ក្នុងខ្លួន។ អ្នកមានធម៌ក្នុងខ្លួនរមែងបានសុខកាយសប្បាយចិត្តក្នុងបច្ចុប្បន្ន ដោយលោកមិនមានទោសសត្រូវជាមួយអ្នកដទៃ ដែលធ្វើឲ្យអ្នកដទៃចងអាឃាតព្យាបាទលោកឡើយ។ ផ្ទុយទៅវិញ ធ្វើឲ្យអ្នកដទៃគោរពកោតក្រែងជឿទុកចិត្ត ហើយកិច្ចការសំខាន់ៗរបស់សង្គមតែងតែពិគ្រោះជាមួយលោក។

សេចក្តីសុខសន្តិភាពនិងវឌ្ឍនភាពនៃសង្គមមនុស្សត្រូវកើតឡើងពីមនុស្សម្នាក់ៗទៅ ហើយបើមនុស្សគ្រប់រូបមានធម៌ក្នុងខ្លួននឹងធ្វើឲ្យសង្គមគ្រួសារ ធ្វើឲ្យប្រទេស និងធ្វើឲ្យពិភពលោកទាំងមូលបានសុខសន្តិភាព។ ពាក្យថា មានធម៌ក្នុងខ្លួនតាមន័យរបស់ព្រះពុទ្ធសាសនា ស្មើគ្នានឹងពាក្យដែលផ្លូវលោក

គេប្រើសព្វថ្ងៃថា ជាអ្នកគោរពសិទ្ធិអ្នកដទៃនេះឯង។ អ្នកមានសីលក្នុងខ្លួនឈ្មោះថា មិនបៀតបៀនអ្នកដទៃ អ្នកធ្វើទានឈ្មោះថា ជួយសង្គ្រោះអ្នកដទៃ អ្នកចំរើនមេត្តាភាវនាឈ្មោះថា ធ្វើចិត្តឲ្យស្ងប់ មិនគិតធ្វើអំពើបាបអ្នកដទៃ។ ក្នុងមង្គលសូត្រមានពាក្យមួយឃ្លាថា **អត្តសម្មាបណិធិ** ប្រែថា ការដំកល់ខ្លួនដ៏ប្រពៃក្នុងបច្ចុប្បន្នជា**មង្គល**ដ៏ឧត្តម។ ពាក្យថា **មង្គល** ប្រែថា សេចក្តីចំរើន គឺចំរើនដោយសេចក្តីសុខ។ ដំកល់ខ្លួនដោយប្រពៃគឺដំកល់ខ្លួនក្នុងទានសីលភាវនានេះឯង។ មានធម៌ក្នុងខ្លួនក៏ស្មើនឹងពាក្យថា មានទានសីលភាវនាក្នុងខ្លួនដូចគ្នាដែរ។

ពិភពលោកសព្វថ្ងៃនេះ គេអប់រំមនុស្សឲ្យស្គាល់តម្លៃមនុស្ស អប់រំមនុស្សឲ្យគោរពសិទ្ធិមនុស្ស គឺអប់រំមនុស្សឲ្យគោរពច្បាប់ជាតិនិងច្បាប់អន្តរជាតិ។ អ្នកមានធម៌ក្នុងខ្លួននៃពុទ្ធភាសិតខាងដើមនេះ ឈ្មោះថា គោរពសិទ្ធិអ្នកដទៃនេះឯង។ ពាក្យថា មានធម៌ក្នុងខ្លួននេះ មានជម្រៅជាងច្បាប់ផ្លូវអាណាចក្រទៅទៀត គឺជាបុគ្គលស្ងប់មិនប្រព្រឹត្តអំពើបៀតបៀនគ្រប់យ៉ាងដល់បុគ្គលដទៃ សូម្បីគិតបៀតបៀនតាមផ្លូវចិត្តក៏មិនគិតផង។

មិនតែប៉ុណ្ណោះសីលធម៌ព្រះពុទ្ធសាសនា មានកម្រឹតខ្ពស់ណាស់ សូម្បីតែសត្វតិរច្ឆាន ក៏ព្រះពុទ្ធណែនាំកុំឲ្យបៀតបៀន

កុំឲ្យសម្លាប់គ្នា។ ដូច្នេះ បើពិភពលោកនាំគ្នាសិក្សានាំគ្នាប្រតិបត្តិតាមធម៌ព្រះពុទ្ធត្រង់ពុទ្ធភាសិតនេះ មនុស្សគ្រប់រូបនឹងមានធម៌ក្នុងខ្លួន នោះនឹងធ្វើឲ្យសង្គមតូច សង្គមធំរហូតដល់សហគមន៍ពិភពលោកបានសុខសន្តិភាព ហើយអំពើហឹង្សាគ្រប់យ៉ាងរមែងពុំកើតឡើងឡើយ។ ក៏ដូចគ្នានឹងសង្គ្រាមគ្រប់ប្រភេទក៏មិនកើតឡើងដែរ ព្រោះមនុស្សគ្រប់រូបមានធម៌ក្នុងខ្លួន។ បានសេចក្ដីថា បើបុគ្គលមួយរូបៗមានធម៌ក្នុងខ្លួន បានសុខខ្លួនឯងផង ធ្វើឲ្យសង្គមមនុស្សបានសុខផង។ បើនិយាយដល់ជម្រៅព្រះពុទ្ធសាសនា បើអ្នកមានធម៌ក្នុងខ្លួនដល់កម្រិតខ្ពស់នឹងបានសម្រេចព្រះនិព្វានជាការរំលត់ទុក្ខ ចេញផុតពីការកើតចាស់ឈឺស្លាប់ដែលជាទុក្ខធំបំផុតក្នុងសង្សារវដ្ដ។ ដូច្នេះ បុគ្គលមានធម៌ក្នុងខ្លួន គឺកុសលធម៌ដូចបានពោលមកហើយ អំពើល្អនោះតែងរក្សាបុគ្គលនោះឲ្យបានសេចក្ដីសុខចំរើន រហូតបានសម្រេចព្រះនិព្វានជាការរំលត់ទុក្ខ។

ឞឞឞឞឞ

# ៤- ពាក្យខ្មែរថា ចាញ់បានជាព្រះឈ្នះបានជាមារ

ពាក្យថា **ចាញ់បានជាព្រះ ឈ្នះបានជាមារ** នេះ ជាពាក្យលេចចេញមកពីមជ្ឈដ្ឋាន អ្នកកាន់ពុទ្ធសាសនាខ្មែរ។ ពាក្យចាញ់និងឈ្នះតាមផ្លូវលោកនិងផ្លូវធម៌មានន័យខុសគ្នា។ ជំនះផ្លូវលោកគឺគេឲ្យតម្លៃទៅលើអ្នកដែលមានប្រៀបទៅលើគូប្រជែងម្ខាងទៀត ដូចជាឈ្នះដោយលេងល្បែងផ្សេងៗ ឈ្នះដោយច្បាំងគ្នា ដោយម្ខាងមានប្រៀបទៅលើគូប្រជែងម្ខាងទៀតជាដើម។ ឯពាក្យថា ចាញ់គឺចាញ់គូប្រជែងម្ខាងនោះឯង។ តាមន័យផ្លូវធម៌ ឈ្នះរបៀបនេះពុំមែនជាជំនះពិតប្រាកដ ជាជំនះតាំងនៅជាស្ថាពរឡើយ ជាជំនះនឹងត្រឡប់ចាញ់វិញ ហើយប្រកបដោយការចងពៀរនឹងគ្នាទៀតផង។ ចំណែកជំនះផ្លូវធម៌វិញគឺឈ្នះផ្លូវចិត្តខ្លួនឯងដោយមិនធ្វើអំពើបាបគ្រប់យ៉ាងដោយមានចិត្តបរិសុទ្ធ ឈ្នះសត្រូវគឺកិលេសគ្រឿងសៅហ្មងចិត្ត។ បានសេចក្ដីតាមផ្លូវធម៌ថា ឈ្នះសេចក្ដីអាក្រក់ខ្លួនឯងដោយការពុំបៀតបៀនអ្នកដទៃ ឈ្មោះថាជាអ្នកឈ្នះពិតប្រាកដ។ អ្នកឈ្នះអ្នកដទៃដោយអំពើហឹង្សា អ្នកនោះតែងមានសេចក្ដីក្ដៅក្រហាយខ្លួនឯង បង្កើតអសន្តិសុខនៅក្នុងចិត្តរបស់ខ្លួនជានិច្ច បានន័យ

ថា ជាអ្នកចាញ់ខ្លួនឯង។ អំពើអាក្រក់ដែលកើតអំពើការចងគំនុំផ្ទាល់ខ្លួនក្តី តាមផ្លូវនយោបាយក្តី ឈ្មោះថាជាអ្នកចាញ់ ព្រោះអំពើអាក្រក់នោះនឹងវិលត្រឡប់ឲ្យទុក្ខដល់ខ្លួនវិញ។ អ្នកដែលរំលោភឈ្លានពានគេ ឈ្មោះថាជាអ្នកចាញ់ គឺចាញ់ដោយសារតែបណ្តោយឲ្យអំពើអាក្រក់ដែលស្ថិតនៅក្នុងចិត្តរបស់ខ្លួនឈ្នះ។

ចំណែកបុគ្គលដែលមិនបៀតបៀនអ្នកដទៃមិនរំលោភសិទ្ធិអ្នកដទៃ ឈ្មោះថាជាអ្នកឈ្នះ គឺឈ្នះសេចក្តីអាក្រក់មិនឲ្យកើតមានក្នុងចិត្តរបស់ខ្លួន អ្នកនោះនឹងត្រូវបានរង្វាន់តបវិញ គឺការស្រឡាញ់រាប់អានពីជនទូទៅដែលជាហេតុនាំឲ្យបានសេចក្តីសុខ។ ពាក្យថា **ចាញ់បានជាព្រះ** បើនិយាយពីព្រះពុទ្ធអ្នកត្រាស់ដឹង គឺចាញ់ត្រង់ព្រះអង្គពុំធ្វើអំពើអាក្រក់ដូចបុគ្គលពាលតែចាញ់ដើម្បីឈ្នះ គឺឈ្នះកិលេសតណ្ហា ឈ្នះអំពើអាក្រក់គ្រប់យ៉ាង ហើយទីបំផុតព្រះអង្គមានជ័យជំនះបានត្រាស់ជាព្រះពុទ្ធ។ ពាក្យថា ព្រះពុទ្ធឈ្នះមារ គឺឈ្នះសេចក្តីអាក្រក់គ្រប់យ៉ាងមានកិលេសមារជាដើម។ ក្នុងទីនេះបើ**ព្រះ**ឲ្យន័យថាប្រសើរវិញ គឺអ្នកដែលមិនធ្វើអំពើបាបនេះហើយ ជាអ្នកប្រសើរ។ ពាក្យថាចាញ់នេះពុំមែនបានន័យថា មិនតស៊ូដោះស្រាយបញ្ហាជីវិតឡើយ ផ្ទុយទៅវិញ ពាក្យថាចាញ់នេះ គឺចាញ់មិនធ្វើបាប ដើម្បី

ជ័យជំនះតាមលក្ខណៈរបស់លោកអ្នកសប្បុរសតាមមាគ៌ាគតិ
បណ្ឌិត ឈ្មោះថាជាអ្នកតស៊ូអត់សង្កត់មិនសាងអាក្រក់ ឈ្មោះ
ថាជាអ្នកឈ្នះ។ ឯអ្នកដែលសាងអាក្រក់ទីបំផុតនឹងត្រូវទទួល
បរាជ័យដោយអំពើអាក្រក់របស់ខ្លួន ឈ្មោះថាជាអ្នកចាញ់។

ಖಖಖಖಖ

# ៥- ការមិនមានរោគ ជាលាភដ៏ប្រសើរ

ពុទ្ធភាសិតថា ការមិនមានរោគជាលាភដ៏ប្រសើរនេះ ចេញមកពីបាលីថា **អរោគ្យា បរមា លាភា**។ ពុទ្ធភាសិតនេះ មានន័យថា ការមិនមានរោគជាលាភឬជាការបានដ៏ប្រសើរ ព្រោះការបានវត្ថុដទៃ ដូចជាការបានទ្រព្យសម្បត្តិ ការមានបញ្ញា ពុំអាចធ្វើចិត្តឲ្យរីករាយ ព្រោះពុំអាចប្រើប្រាស់វត្ថុទាំងនោះបានដោយហេតុមានជម្ងឺ។ បើពុំមានរោគវិញ ទោះបីខ្សត់ខ្សោយទ្រព្យសម្បត្តិ គ្មានយសសក្តិអ្វីក៏ដោយ ក៏នៅតែសប្បាយចិត្តហើយមានលទ្ធភាពយកកម្លាំងកាយកម្លាំងប្រាជ្ញាទៅប្រើប្រាស់ដើម្បីប្រយោជន៍ខ្លួននិងប្រយោជន៍សង្គមបាន។ ចំពោះការប្រតិបត្តិធម៌វិញ បើមានរោគពុំអាចប្រតិបត្តិធម៌ឲ្យបានពេញបរិបូរណ៌ឡើយ។ នៅសម័យពុទ្ធកាល ព្រះពុទ្ធក៏មានវេជ្ជបណ្ឌិតប្រចាំការសំរាប់ពិនិត្យព្រះសុខភាពរបស់ព្រះអង្គដែរ។ ការមិនមានរោគបានសេចក្តីថា មនុស្សកើតមកតាំងពីក្មេងពុំសូវឈឺមានសុខភាពល្អ បើឈឺក៏ឈឺបន្តិចបន្តួចដោយការប្រែប្រួលរដូវត្រជាក់ក្តៅ។ នៅក្នុង**គិរិមានន្ទសូត្រ** ពោលថា កាល

ណាមានរូបតែងមានរោគ មនុស្សកើតមកពុំឈឺសោះពុំមានឡើយ។ ប៉ុន្តែ ការមិនមានរោគក្នុងពុទ្ធភាសិតនេះ សំដៅយកការមិនមានរោគប្រចាំកាយ គឺការឈឺជាប់ជានិច្ច។

ព្រះពុទ្ធបានសំដែងក្នុងបរមត្ថអភិធម្មថា រូបកាយរបស់មនុស្សសត្វជាអនត្តា ប្រែថាមិនមានជារបស់ខ្លួន ព្រោះជាធម្មជាតកើតពីគ្រឿងផ្សំគឺធាតុទឹកដីភ្លើងខ្យល់ មិនស្តាប់បង្គាប់ ប្រព្រឹត្តទៅតាមច្បាប់ធម្មជាត គឺកើតចាស់ឈឺស្លាប់។ តាមបទវិគ្គហៈថា ធម្មជាតណាកើតឡើងហើយវិនាសទៅវិញ ធម្មជាតនោះ ហៅថារូប។ រូបនេះលោកប្រៀបដូចដុំនៃពពុះទឹកដែលប៉ោងហើយបែកធ្លាយទៅវិញ។ ទោះបីរូបប្រកបដោយធម៌អនត្តាមិនមានជារបស់ខ្លួន ក៏ព្រះពុទ្ធបានបង្រៀនឲ្យថែរក្សាខ្លួនប្រាណឲ្យមានសុខភាពល្អ ដោយឲ្យមានអនាម័យវិធីការពារកុំឲ្យកើតរោគ។ កាលណាមានរោគ គឺមានជម្ងឺ ព្រះពុទ្ធបានឲ្យប្រើថ្នាំព្យាបាលរោគ ដូចព្រះអង្គបានអនុញ្ញាតឲ្យព្រះសង្ឃប្រើថ្នាំក្នុងពេលមានអាពាធ។ កាលណាជីវិតរស់នៅយូរមានសុខភាពល្អ ការប្រតិបត្តិធម៌គឺការបំពេញអំពើជាកុសលក៏បានយូរ។ ប៉ុន្តែ បើរស់នៅយូរបែរជាប្រព្រឹត្តអំពើអាក្រក់ទៅវិញ ការរស់នៅយូរនោះគ្មានបានប្រយោជន៍អ្វីឡើយ ផ្ទុយទៅវិញ ការរស់

នៅយូរនាំឲ្យសាងអំពើបាបកាន់តែច្រើនឡើង។ កាលណាកាយមានជម្ងឺ ការប្រតិបត្តិធម៌ក៏មិនងាយធ្វើចិត្តឲ្យស្ងប់ឡើយ ដោយចិត្តជាប់នឹងការឈឺចុកចាប់ ព្រោះកាយនិងចិត្តមានទំនាក់ទំនងគ្នា។ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ មនុស្សសត្វដែលកើតរោគតិចច្រើនជាងគ្នា ដោយសារអំពើល្អអាក្រក់របស់ខ្លួនដែលបានកសាងពីមុនមក ផ្សំគ្នានឹងការថែទាំខ្លួនក្នុងបច្ចុប្បន្នផង។

ផ្លូវអាណាចក្រ បានបង្កើតមន្ទីរពេទ្យកាន់តែច្រើនឡើង ហើយបុគ្គលិកពេទ្យក៏កាន់តែកើនឡើងដែរ ដើម្បីតម្រូវដល់អ្នកជម្ងឺដែលកើតមានកាន់តែច្រើនឡើង។ មានជម្ងឺខ្លះ ពេទ្យមិនទាន់រកថ្នាំឃើញនៅឡើយ ដើម្បីសម្លាប់មេរោគនៃជម្ងឺទាំងនោះ។ ជម្ងឺខ្លះកើតពីមនុស្សខ្លួនឯងបង្កើតឡើង ដូចជារោគកើតពីការផឹកស្រា ការលេងស្រី ការជក់បារី ការជក់គ្រឿងញៀនជាដើម ដែលព្រះពុទ្ធឲ្យមនុស្សវៀរចាក ព្រោះជាអំពើអបាយមុខនាំឲ្យកើតរោគ។ មានជម្ងឺខ្លះពេទ្យអាចព្យាបាលឲ្យជា តែមានជម្ងឺខ្លះពេទ្យមិនអាចព្យាបាលឲ្យជាឡើយ មានអ្នកជម្ងឺខ្លះត្រូវស្លាប់។ ជម្ងឺធ្ងន់ស្រាលកែបានកែមិនបានមានហេតុផលរបស់វា តាមច្បាប់កម្មផល ពុំមែនបណ្តាលមកពីព្រះជាម្ចាស់អង្គណាឡើយ។

ជម្ងឺមួយប្រភេទដែលមិនអាចកែបាន គឺជម្ងឺចាស់ជរា ព្រោះកាលណាចាស់ជរាទៀងតែស្លាប់ ដូចពាក្យថា គាត់ស្លាប់ដោយជរាពាធ បើនៅក្មេងកើតរោគស្លាប់ត្រូវពោលថា គាត់ស្លាប់ដោយរោគាពាធ។ ដោយឃើញថា មនុស្សកើតមកត្រូវស្លាប់ទៅវិញគួរឲ្យសង្វេគតក់ស្លុតនេះហើយ បានជាមនុស្សគួរលើកយកមកពិចារណា ហើយមិនគួរសាងអំពើបាបមានការបៀតបៀនគ្នាជាដើមឡើយ។ ពុទ្ធសាសនិកជនខំប្រតិបត្តិធម៌ដើម្បីឲ្យបានសម្រេចព្រះនិព្វានជាការរំលត់ទុក្ខ ព្រោះឃើញភ័យក្នុងការកើតចាស់ឈឺស្លាប់នេះឯង។ សាសនាដទៃថា បើចង់ផុតទុក្ខ ត្រូវជឿព្រះទៅរស់នៅជាមួយព្រះអង្គនៅស្ថានសួគ៌ឬនៅស្ថានព្រហ្ម។ ព្រះពុទ្ធសំដែងថា ការទៅស្ថានសួគ៌ឬចុះនរកដោយសារអំពើរបស់ខ្លួន ពុំមែនដោយសារព្រះជាម្ចាស់អង្គណាឡើយ ព្រោះនៅក្នុងភពប្រកបដោយជាតិមានខន្ធ៥។ ព្រះពុទ្ធសំដែងក្នុងអរិយសច្ច៤ ទុក្ខសច្ចបានដល់ការមានខន្ធ៥ជាតួទុក្ខ ឯព្រះនិព្វានជាការរំលត់ខន្ធ៥ ជាបរមសុខ។

ឲឲឲឲឲ

# ៦- ធម្មរសឈ្នះអស់រសទាំងពួង

ពាក្យថា **ធម្មរសឈ្នះអស់រសទាំងពួង** នេះចេញមកពីពុទ្ធភាសិតជាបាលីថា **សព្វរសំ ធម្មរសោ ជិនាតិ**។ ពាក្យនេះពោលបញ្ជាក់អំពីរសទាំងអស់ក្នុងលោកប្រៀបធៀបនឹងរសព្រះធម៌ ថារសព្រះធម៌ប្រសើរដាច់អស់រសទាំងពួង។ រសក្នុងលោកដូចជារសដែលកើតអំពីការស្រឡាញ់ចូលចិត្តក្នុងកាមគុណ៥គឺ **រូប សម្លេង ក្លិន រស** និង **សម្ផស្ស** ដែលមនុស្សលោកតែងស្រឡាញ់ចូលចិត្តនោះ គឺបានសប្បាយបានសុខស្រួលតែក្នុងមួយខណៈមួយពេលប៉ុណ្ណោះ ក៏ត្រូវបាត់ទៅវិញ។ ក្នុង**បដិច្ចសមុប្បាទធម៌** និយាយថា វេទនាជាសុខជាទុក្ខ កើតមកអំពីផស្សៈ គឺការប៉ះទង្គិចរវាងអាយតនៈខាងក្នុង គឺភ្នែកត្រចៀកច្រមុះអណ្តាតកាយនិងមនោ ជាមួយនឹងរូបសម្លេងក្លិនរសសម្ផស្សនិងធម្មៈ(វត្ថុដែលចិត្តតោង)។ ធម្មជាតិទាំងនេះ សុទ្ធតែជាសភាវៈពុំទៀង ដូច្នេះ វេទនាជាសុខជាទុក្ខ ក៏ស្ថិតនៅក្នុងសភាពពុំទៀងតែងតែប្រែប្រួលដូចគ្នា។ ភ្នែកប៉ះនឹងរូប ត្រចៀកប៉ះនឹងសម្លេង កើតការស្រឡាញ់ចូលចិត្តថារូបស្អាតរូបល្អសម្លេងពីនោះ ក៏កើតចិត្តសប្បាយជាតួសោមនស្សវេទនាផ្លូវចិត្ត

បានតែមួយខណៈមួយពេលក៏បាត់ទៅវិញ។ ច្រមុះប៉ះនឹងក្លិន មានចិត្តរីករាយនឹងក្លិនក្រអូបពុំយូរប៉ុន្មានក៏បាត់ទៅវិញ។ អណ្តាតប៉ះនឹងរសជាតិអាហារបានឆ្ងាញ់តែត្រឹមអណ្តាត លុះលេបផុតពីបំពង់កទៅ ការឆ្ងាញ់ពិសារនោះក៏បាត់ទៅ។ ចិត្តនឹកគិតប៉ះអារម្មណ៍ជាទីសប្បាយ ពុំយូរប៉ុន្មានដូរផ្លាស់មកទោមនស្សវិញ។ នេះជារសកើតមកពីការត្រេកអរក្នុងផ្លូវកាមគុណក្នុងកាមភព។ ចំណែកសុខក្នុងរូបភពនិងអរូបភព ក៏ស្ថិតនៅក្នុងសភាពប្រែប្រួលដូរផ្លាស់ទាំងអស់ ព្រោះថាភពទាំងបីនេះស្ថិតនៅក្នុងសភាពពុំទៀងជាទុក្ខ(បរិណាមទុក្ខ)គឺទុក្ខកើតអំពីការប្រែប្រួល និងជាអនត្តា។

ចំណែក ធម្មរសប្រែថារសនៃព្រះធម៌ មានតម្លៃកាត់ថ្លៃពុំបាន។ ព្រះបរិយត្តិធម៌ បានដល់ព្រះត្រៃបិដកជាធម៌ គឺព្រះពុទ្ធសំដែងល្អហើយ សំដែងត្រឹមត្រូវហើយ ជាមាគ៌ាដឹកនាំសត្វឲ្យចេញចាកទុក្ខ។ ព្រះធម៌របស់ព្រះពុទ្ធបានបង្ហាញនូវមាគ៌ាជីវិតពិតប្រាកដ រមែងញុំាងអ្នកប្រតិបត្តិតាមឲ្យបានម៉ត់ចត់ នឹងបានទទួលនូវរសមួយនៅទីបំផុត ហៅថាវិមុត្តិរសឬនិព្វានរស ជាការផុតទុក្ខលែងវិលកើតវិលស្លាប់ក្នុងសង្សារវដ្ត។ រសជាតិនៃព្រះធម៌តែងតែមានតម្លៃគ្រប់កាលសម័យនិងគ្រប់ទីកន្លែងឲ្យតែគេ

ប្រតិបត្តិនូវធម៌ឲ្យបានត្រឹមត្រូវ។ សង្គមមនុស្ស បើមនុស្សមានមេត្តាករុណាពុំបៀតបៀនគ្នា នឹងបានទទួលនូវរសមួយគឺសង្គមរស គឺធ្វើឲ្យសង្គមមានសុខសន្តិភាព។ ការក្រេបជញ្ជក់យករសជាតិព្រះធម៌ ឈ្មោះថា ក្រេបយកអមតធម៌ ប្រែថា ធម៌ពុំស្លាប់ បានដល់ព្រះនិព្វាន ដែលព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើមបានសម្រេចហើយ។

បើប្រៀបធៀបសេចក្តីសុខក្នុងកាមគុណ៥ វាបានសុខខ្លះ ប៉ុន្តែសេចក្តីសុខនោះពុំយូរប៉ុន្មាន វាប្រែប្រួលទៅជាក្តៅក្រហាយចិត្តប្រកបដោយការសោកសៅវិញ រហូតប្រព្រឹត្តធ្វើអំពើអកុសលថែមទៀត។ ចំណែករសព្រះធម៌ រមែងញុំាងឲ្យមនុស្សសត្វដែលប្រតិបត្តិតាមឲ្យដល់នូវភាពស្ងប់ពុំក្តៅក្រហាយដោយភ្លើងកិលេសគឺ**លោភៈទោសៈមោហៈ** រមែងបានសុខក្សេមក្សាន្តក្នុងលោកនេះ លោកខាងមុខ និងសុខជាន់ខ្ពស់គឺ **ព្រះនិព្វាន**។ បើធម្មរសកើតមានក្នុងលោកនឹងធ្វើឲ្យសង្គមមនុស្សក្នុងសាកលលោកបានសុខសន្តិភាព ឯការច្បាំងគ្នាប្រកបដោយអំពើហឹង្សារមែងពុំកើតមានឡើយ។ ដូច្នេះ ធម្មរសពិតជាឈ្នះអស់រសទាំងពួង។

ឃឃឃឃឃ

# ៧- សមភាពផ្លូវលោកនិងផ្លូវធម៌

## ១. សមភាពផ្លូវលោក

ពាក្យថា **សមភាព** ប្រែថា ភាពស្មើគ្នា ដំណើរស្មើមុខគ្នា ប៉ុនគ្នាឬដូចគ្នាចំពោះមុខច្បាប់។ ដូចជាពលរដ្ឋម្នាក់មានសិទ្ធិរៀនសូត្រ សិទ្ធិនិយាយបញ្ចេញមតិ សិទ្ធិរកស៊ី សិទ្ធិបង្កើតសមាគម សិទ្ធិធ្វើរដ្ឋការ សិទ្ធិខាងជំនឿ សិទ្ធិសរសេរសារពត៌មាន សរសេរសៀវភៅ ទស្សនាវដ្ដី សិទ្ធិធ្វើកូដកម្មបាតុកម្ម ពលរដ្ឋដទៃទៀតក៏មានសិទ្ធិនេះដូចគ្នា ទោះបីខុសគ្នាដោយទ្រព្យសម្បត្តិដោយឋានៈដោយជាតិត្រកូលក៏ដោយ។ នេះជាសមភាពប្រកបដោយយុត្តិធម៌ដែលប្រទេសកាន់របបប្រជាធិបតេយ្យនិងច្បាប់អង្គការសហប្រជាជាតិបានចែងនិងអនុវត្តមកហើយ។ បើនិយាយអំពីទោសកំហុសដែលត្រូវឡើងតុលាការ បើប្រជាពលរដ្ឋធ្វើខុសឡើងតុលាការ អ្នករដ្ឋការគ្រប់ដំណែងដែលធ្វើខុសក៏ត្រូវឡើងតុលាការកាត់ទោសដូចគ្នា។

## ២. សមភាពផ្លូវធម៌

សមភាពតាមអត្ថន័យផ្លូវធម៌របស់ព្រះពុទ្ធសាសនា គឺស្មើគ្នាចំពោះមុខអំពើរបស់ខ្លួន។ សេចក្ដីថា អ្នកមានក្ដី អ្នកក្រក្ដី អ្នកធំក្ដី អ្នកតូចក្ដី បើមានចិត្តសៅហ្មងប្រព្រឹត្តធ្វើអំពើអាក្រក់ ត្រូវតែ

ទទួលផលអាក្រក់តាមអំពើរបស់ខ្លួន បើមានចិត្តបរិសុទ្ធប្រព្រឹត្ត ល្អ ក៏ត្រូវទទួលផលល្អតាមអំពើរបស់ខ្លួនដែរ។ នេះជាសមភាព ចំពោះមុខអំពើរបស់ខ្លួន ដែលជាច្បាប់ធម្មជាតិសាកលប្រកប ដោយយុត្តិធម៌របស់ព្រះពុទ្ធសាសនា។ កំពស់និងទំនាបរបស់ មនុស្សស្ថិតនៅលើអំពើរបស់ខ្លួន បានសេចក្តីថា មនុស្សមាន តម្លៃខ្ពស់ខ្ពង់និងថោកទាបត្រូវកើតចេញមកអំពីអំពើល្អអាក្រក់ របស់ខ្លួន។ បើគេប្រព្រឹត្តល្អដោយការវាចាចិត្ត គេជាមនុស្ស ខ្ពង់ខ្ពស់ថ្លៃថ្នូរ បើគេប្រព្រឹត្តអាក្រក់ដោយកាយវាចាចិត្ត គេជា មនុស្សថោកទាប គឺយកអំពើល្អនិងអំពើអាក្រក់ជាខ្នាតសំរាប់ វាស់ ពុំមែនយកទ្រព្យសម្បត្តិ បុណ្យសក្តិ ជាតិត្រកូលជាខ្នាត សំរាប់វាស់ឡើយ។ បើមនុស្សមានទ្រព្យសម្បត្តិស្តុកស្តម្ភ មាន បុណ្យសក្តិធំដុំ មានជាតិត្រកូលខ្ពង់ខ្ពស់ តែប្រព្រឹត្តអំពើអាក្រក់ ដោយកាយវាចាចិត្ត ចាត់ទុកជាមនុស្សថោកទាប។ ផ្ទុយទៅ វិញ បើមនុស្សក្រីក្រលំបាកតោកយ៉ាក ឥតបុណ្យឥតសក្តិ មាន ជាតិត្រកូលទាប តែជាមនុស្សប្រព្រឹត្តល្អដោយកាយវាចាចិត្ត មិនបៀតបៀនអ្នកដទៃ ត្រូវចាត់ទុកជាមនុស្សខ្ពង់ខ្ពស់ថ្លៃថ្នូរ។ ចំពោះសមភាពខាងការគោរពព្រះពុទ្ធសាសនា គឺមនុស្សគ្រប់ ជាន់ថ្នាក់អាចមានសិទ្ធិចូលកាន់ព្រះពុទ្ធសាសនាបានដូចគ្នា

មាននាមជាទាយកទាយិកា ជាឧបាសកឧបាសិកា ជាភិក្ខុសាមណេរតាមកម្រឹតធម៌វិន័យដែលខ្លួនអាចទទួលកាន់យកបានតាមសទ្ធាជ្រះថ្លា។ មួយទៀត បុគ្គលគ្រប់រូបមានសិទ្ធិត្រាស់ជាព្រះពុទ្ធបានដូចគ្នាឲ្យតែកសាងបារមីទាំង១០បានពេញបរិបូរណ៌។

សមភាពនេះ ផ្លូវលោកនិងផ្លូវធម៌សឹងតែដូចគ្នា ត្រង់ន័យព្រះពុទ្ធសាសនាថា អ្នកសាងអំពើអាក្រក់ត្រូវទទួលផលអាក្រក់ ទោះអ្នកមានក្តីអ្នកក្រក្តីអ្នកធំក្តីអ្នកតូចក្តីផ្សេងគ្នាដោយជាតិត្រកូលក្តី។ ឯផ្លូវលោកក៏ចែងថា ជនណាប្រព្រឹត្តរំលោភច្បាប់ឬរំលោភសិទ្ធិមនុស្សត្រូវមានទោស ទោះអ្នកមានក្តី អ្នកក្រក្តី អ្នកធំក្តី អ្នកតូចក្តី អ្នកមានជាតិត្រកូលផ្សេងគ្នាក្តី។ បានសេចក្តីថាបើប្រជាពលរដ្ឋធ្វើខុសច្បាប់រដ្ឋ ត្រូវឡើងតុលាការកាត់សេចក្តី អ្នករដ្ឋការគ្រប់ដំណែងរហូតដល់រដ្ឋមន្ត្រីបើធ្វើខុសច្បាប់រដ្ឋ ក៏ត្រូវឡើងតុលាការកាត់សេចក្តីវិនិច្ឆ័យទោសដូចគ្នា ដូចប្រជាពលរដ្ឋដែរ។ នេះជាភាពស្មើគ្នាចំពោះមុខច្បាប់ ពុំមែនស្មើគ្នាដោយទ្រព្យសម្បត្តិដូចលទ្ធិកុម្មុយនិស្តចែងទេ ព្រោះនិស្ស័យវាសនាការព្យាយាមរបស់មនុស្សមានលក្ខណៈផ្សេងៗគ្នា។ ប៉ុន្តែព្រះពុទ្ធសាសនាចែងអំពីការទទួលផលនៃអំពើច្បាស់លាស់

និងជ្រៅជាងច្បាប់ផ្លូវលោក គឺច្បាប់ផ្លូវធម៌ ចែងថា អ្នកប្រព្រឹត្ត អំពើណាមួយ ត្រូវតែទទួលផលនៃអំពើរបស់ខ្លួន ទោះបីអំពើ ដែលធ្វើនោះ គ្មានគេដឹងឮក៏ដោយ។ ចំណែកច្បាប់ផ្លូវលោក បុគ្គលត្រូវទទួលផលនៃអំពើ លុះត្រាតែមានភ័ស្តុតាងនិងសាក្សី ដឹងឮថា បុគ្គលនោះបានប្រព្រឹត្តធ្វើអំពើនោះពិតមែន។

# ៨- វិជ្ជាផ្លូវលោកនិងផ្លូវធម៌

**១. វិជ្ជាផ្លូវលោក** បានដល់វិជ្ជាគ្រប់យ៉ាងដែលមនុស្សបង្កើតឡើង តាមការត្រិះរិះឬពិសោធធម្មតា មានការពិតទៅតាមលោកិយសច្ចៈ ដូចជាចំណេះខាងវិជ្ជាពេទ្យ ខាងអក្សរសាស្ត្រ ខាងទស្សនវិជ្ជា ខាងបច្ចេកទេសវិទ្យាសាស្ត្រផ្សេងៗជាដើម។ វិជ្ជាទាំងនេះ អាចយកទៅបំរើនិងសម្រួលជីវភាពរបស់មនុស្សនិងសង្គមមនុស្សបានយ៉ាងប្រសើរណាស់ បើគេយកទៅប្រើក្នុងផ្លូវត្រូវប្រកបដោយសីលធម៌។ វិជ្ជារបស់វិទ្យាសាស្ត្រមួយផ្នែកទៀត ធ្វើឲ្យសង្គមមនុស្សមានសេចក្ដីអន្តរាយ គឺការសង្កើតគ្រឿងសាស្ត្រាវុធ តើការបង្កើតអាវុធដើម្បីអ្វី? គឺពិតជាយកទៅសម្លាប់គ្នា។ វិជ្ជាផ្លូវលោកអាចជួយសម្រួលការរស់នៅរបស់មនុស្សឲ្យបានសុខស្រួលបានខ្លះ ប៉ុន្តែពុំអាចកំចាត់សេចក្ដីទុក្ខឲ្យអស់ដោយដាច់ខាតបានឡើយ ព្រោះបញ្ហាចាស់ឈឺស្លាប់ បញ្ហាព្រាស់ប្រាស់គ្នា វិជ្ជាផ្លូវលោកពុំអាចដោះស្រាយបានឡើយ។ អ្នកចេះវិជ្ជាផ្លូវលោកផ្នែកណាមួយ ទុកជាការប្រសើរមួយហើយ សំរាប់ដោះស្រាយបញ្ហាសង្គមមនុស្ស ប៉ុន្តែអស់លោកទាំងនោះនៅមានអវិជ្ជានៅឡើយ អវិជ្ជាព្រោះពុំដឹង

សច្ចធម៌តាមវិជ្ជាផ្លូវធម៌របស់ព្រះពុទ្ធសាសនា ដែលជាវិជ្ជាធ្វើទុក្ខឲ្យអស់ទៅបាន គឺវិជ្ជាក្នុងខន្ធ៥មានរូបក្ខន្ធជាដើមដែលប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា។ វិជ្ជាផ្លូវលោកពុំអាចកំចាត់បង់កិលេសតណ្ហា អវិជ្ជាដែលជាហេតុបច្ច័យនាំកើតខន្ធ៥បានឡើយ។ មួយទៀត សេចក្តីសុខពុំមែនកើតឡើងតែពីគ្រឿងសម្ភារៈប៉ុណ្ណោះទេ ប៉ុន្តែត្រូវកើតមកពីផ្លូវចិត្តផង គឺចិត្តស្ងប់មិនលោភមិនក្រោធមិនវង្វេង។ ពាក្យខ្មែរក៏មាននិយាយថា សុខកាយសប្បាយចិត្ត។ បើសុខកាយមានសម្ភារៈបរិភោគប្រើប្រាស់និងកាយមិនមានរោគ ប៉ុន្តែចិត្តពុំសប្បាយដោយមានវិបត្តិអ្វីមួយ មនុស្សនោះពុំមានសុភមង្គលឡើយ។ ដូច្នេះ វិជ្ជាផ្លូវលោកពុំអាចដោះស្រាយបញ្ហាទុក្ខផ្លូវចិត្តបានឡើយ។

វិជ្ជារបស់ព្រះពុទ្ធសាសនា ជាវិជ្ជាធ្វើឲ្យអ្នកប្រតិបត្តិអស់ទុក្ខ។ អ្នករកឃើញវិជ្ជាផ្លូវធម៌ គឺព្រះសម្មាសម្ពុទ្ធ ព្រះអង្គមានព្រះទ័យបរិសុទ្ធទើបឃើញការពិតនោះ ដែលផ្ទុយគ្នាពីអ្នករកឃើញវិជ្ជាផ្លូវលោកដែលមិនមានចិត្តបរិសុទ្ធ ពុំអាចឃើញសច្ចធម៌ដែលជាផ្លូវប្រតិបត្តិដើម្បីកំចាត់ទុក្ខបានឡើយ។ វិជ្ជាផ្លូវធម៌ជាបរមត្ថវិជ្ជា ជាវិជ្ជាមានសេចក្តីដ៏ជ្រាលជ្រៅដែលជា**វិជ្ជាមានបញ្ញត្តិ**។ ពាក្យថា វិជ្ជមានបញ្ញត្តិ គឺបញ្ញត្តឬដាក់ឈ្មោះត្រូវទៅ

តាមការពិត ដូចពាក្យ បញ្ញត្តិថា**រូប** ប្រែថា ធម្មជាតិដែលកើតឡើងហើយវិនាសទៅវិញដោយក្តៅនិងត្រជាក់ជាដើម ហៅថារូប។បញ្ញត្តិថា**វេទនា** ប្រែថា ធម្មជាតិដែលដឹងឬទទួលសោយអារម្មណ៍ជាសុខជាទុក្ខ ហៅថាវេទនា។ ចំណែកអវិជ្ជាមានបញ្ញត្តិ ដែលវិជ្ជាផ្លូវលោកដាក់ឈ្មោះឬបញ្ញត្តិឡើងមិនត្រឹមត្រូវតាមការពិតឡើយ ជាលោកិយសច្ចៈ ដូចជាឈ្មោះដើមឈើឈ្មោះសត្វ ឈ្មោះមនុស្ស។ គេដាក់ឈ្មោះឬបញ្ញត្តិឡើងដើម្បីកុំឲ្យច្រឡំគ្នា ពុំមែនការពិតនៅក្នុងឈ្មោះនោះឡើយ។ ដូចជាមនុស្សឈ្មោះ**រស់** ពុំមែនមនុស្សនោះរស់រហូតមិនស្លាប់ឡើយក៏ដូចមនុស្សឈ្មោះ**ខា** ពុំមែនមនុស្សនោះពុំឈឺឡើយ នេះជាលោកិយសច្ចៈ។ មគ្គប្រកបដោយអង្គ៨មានសម្មាទិដ្ឋិការយល់ត្រូវជាខាងដើម សម្មាសមាធិ ការដំកល់ចិត្តនឹងត្រូវជាទីបំផុតជាផ្លូវប្រតិបត្តិទៅកាន់ការរំលត់ទុក្ខ។ ផ្លូវប្រតិបត្តិនេះ បើរួមឲ្យខ្លីមានបី គឺ **ទានសីលភាវនា** សំរាប់ពុទ្ធបរិស័ទជាគ្រហស្ថប្រតិបត្តិ និង **សីលសមាធិបញ្ញា** សំរាប់ព្រះសង្ឃប្រតិបត្តិ។ ផ្លូវប្រតិបត្តិនេះ គ្មានតាបសឥសីលទ្ធិសាសនាទស្សនវិទូណារកឃើញឡើយ។ លទ្ធិសាសនាដទៃតែងប្រព្រឹត្តខុស ដូចធ្វើ**តបះយោគៈ** ការធ្វើបាបកាយ ផ្លូវប្រតិបត្តិនេះព្រះអង្គច្រាន

ចោល និងផ្លូវមួយទៀត គឺចិត្តត្រេកអរនឹងកាមគុណ៥ ក៏ព្រះអង្គប្រានចោល ព្រោះជាផ្លូវមិនអាចត្រាស់ដឹង ឃើញអរិយសច្ច៤ មានទុក្ខសច្ចជាដើម ដើម្បីរំលត់ទុក្ខបាន។ មគ្គប្រកបដោយអង្គ ៨នេះ ជា **មជ្ឈិមា បដិបទា** ជាផ្លូវប្រតិបត្តិជាកណ្តាល ដោយឃើញទោសផ្លូវប្រតិបត្តិអមខាងទាំងពីរនេះឯង។ កាលណាប្រតិបត្តិតាមមគ្គប្រកបដោយអង្គ៨ ទើបឃើញទោសក្នុងខន្ធ៥ដែលប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ និងអនត្តា ត្រូវកំណត់ដឹង លះតណ្ហា ធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន។ ព្រះអរហន្តទាំងឡាយ មានព្រះពុទ្ធជាដើមបានដល់ត្រើយគឺព្រះនិព្វានជាការរំលត់ទុក្ខ ឈប់វិលកើតវិលស្លាប់ក្នុងសង្សារវដ្តទៀតហើយ។ អ្នកចេះវិជ្ជាផ្លូវធម៌ហើយខំប្រឹងប្រែងប្រតិបត្តិឲ្យបានម៉ត់ចត់នឹងដល់ការរំលត់ទុក្ខ។ ដូច្នេះ អ្នកមានវិជ្ជាផ្លូវលោកត្រូវសិក្សានិងប្រតិបត្តិតាមផ្លូវធម៌ផង ទើបដល់នូវការរំលត់ទុក្ខដោយដាច់ខាត។

ឲឲឲឲឲ

# ៩- កម្មផលក្នុងព្រះពុទ្ធសាសនា

កម្មផលមាននិយាយស្ទើរតែគ្រប់ទំព័រនៃគម្ពីរព្រះពុទ្ធសាសនា។ ជំនឿក្នុងព្រះពុទ្ធសាសនាគឺការជឿកម្មផលនេះឯង។ ពាក្យថា កម្មមកពីភាសាបាលីថា **កម្មំ** សំស្រ្កឹតថា **កម៌ន** បារាំងនិងអង់គ្លេសថា Action ខ្មែរថា **អំពើឬធំទើ**។ កម្មរបស់ព្រះពុទ្ធសាសនាសំដៅយកអំពើប្រកបដោយចេតនា ពាក្យខ្មែរមួយទៀតថា ប្រកបដោយចិត្តក្លែង ដោយមានពុទ្ធភាសិតថា **ចេតនាហំ ភិក្ខវេ កម្មំ វទាមិ** ប្រែថា ម្នាលភិក្ខុទាំងឡាយតថាគតពោលថា ចេតនាជាតួកម្ម។ អំពើមានចិត្តប្រកបជាមួយដែលហៅថា **សចិត្តកៈ** ទើបហៅថាកម្មដែលឲ្យផលស្របតាមអំពើ ព្រោះមានអំពើខ្លះមិនមានចេតនាផ្លូវចិត្ត ដូចជាដើរជាន់សត្វធ្វើឲ្យវាស្លាប់ដោយអ្នកជាន់នោះពុំបានឃើញព្រោះសត្វនោះល្អិតពេកគ្មានចេតនាសម្លាប់ មិនឈ្មោះថាកម្មដែលនាំឲ្យទទួលផលជាបាបឡើយ។ ពាក្យកម្មនេះ ខ្មែរយកមកប្រើរន័យសេចក្តីទៅជាមានន័យអាក្រក់ទៅវិញ ដូចជាពាក្យថា ខ្ញុំមានកម្មក្រាស់ណាស់ គឺបានសេចក្តីថា បានទទួលសេចក្តីទុកវេទនាតាមផ្លូវកាយឬផ្លូវចិត្តបែបណាមួយ។ តាមពិតកម្មនេះជា

ពាក្យកណ្តាល បើអំពើល្អហៅថា កុសលកម្ម អំពើអាក្រក់ហៅថា អកុសលកម្ម។ កម្មល្អឲ្យផលល្អ កម្មអាក្រក់ឲ្យផលអាក្រក់ គឺអំពើបែបណាផលបែបនោះ។ បុគ្គលដាំពូជបែបណារមែងឲ្យផលបែបនោះ ដូចជាដាំស្រូវឲ្យផលជាស្រូវ ដាំពោតឲ្យផលជាពោត គឺការបញ្ចេញផលមិនឃ្លាតចាកពូជដើម។ យ៉ាងណាមិញ បុគ្គលកសាងអំពើបុណ្យឲ្យផលជាសុខចំរើន សាងអំពើបាបឲ្យផលជាទុក្ខវិនាស។

មានខ្មែរខ្លះយល់ច្រឡំពាក្យ ដោយពោលថា **កម្មជា**យើងមានកម្មបានជាខ្មែរយើងទទួលវេទនារហូតមកដល់សព្វថ្ងៃនេះ ដូច្នេះ គួរផ្លាស់ពាក្យ**កម្ពុជា**នេះឲ្យទៅជាពាក្យផ្សេងពីនេះវិញទៅ។ ពាក្យថា **កម្ម**និងពាក្យថា**កម្ពុជា**នេះ ជាពាក្យពីរសរសេរខុសគ្នានិងមានន័យខុសគ្នាស្រឡះ គឺពាក្យថា **កម្ម** ប្រែថា អំពើដូចបានអធិប្បាយមកហើយ ឯពាក្យថា **កម្ពុជា** មានន័យច្រើនយ៉ាង ន័យម៉្យាងមកអំពី **កម្ពុជ:** ប្រែថា **មាស** ស្មើនឹងពាក្យថា **សុវណ្ណភូមិ** ប្រែថាដែនដីមាស។ តាមពិត សេចក្តីសុខទុក្ខចំរើនវិនាសពុំមែនបណ្តាលមកពីឈ្មោះនោះឡើយ គឺបណ្តាលមកអំពីសកម្មភាពឬអំពើរបស់មនុស្សសត្វវិញទេ។ យ៉ាងណាមិញ **កម្ពុជា**បានសុខបានទុក្ខពុំមែនមកពីឈ្មោះឡើយ តែមកអំពី

ការរៀបចំស្រុកទេសរបស់ជនជាតិកម្ពុជាខ្លួនឯង។ បើរៀបចំនិងដឹកនាំបានល្អនាំឲ្យប្រទេសបានសុខចំរើន បើដឹកនាំមិនបានល្អនាំឲ្យប្រទេសមានទុក្ខ ដូចជាកើតភ្លើងសង្គ្រាមជាដើម ដូច្នេះមិនត្រូវបន្ទោសឈ្មោះឡើយ។ ក្នុងបញ្ហាឈ្មោះនេះ ដូចជាបុគ្គលឈ្មោះ**រស់** ហេតុដូចម្ដេចបានជាបុគ្គលនោះស្លាប់ បុគ្គលឈ្មោះ**ខា** ហេតុដូចម្ដេចបានជាបុគ្គលនោះឈឺជាដើម។ **កម្ម**ក្នុងព្រះពុទ្ធសាសនានិយាយក្នុងកាលទាំងបីគឺពីអតីតកម្ម ទាក់ទងមកបច្ចុប្បន្ន បច្ចុប្បន្នទាក់ទងទៅអនាគតទៀត។ កន្លែងដែលបង្កើតកម្ម គឺកាយវាចានិងចិត្តដែលហៅថា **កាយកម្ម វចីកម្ម** និង**មនោកម្ម**។ កម្មនេះ ខ្លួនឯងជាអ្នកបង្កើត ក្នុងបាលីថា **កម្មស្សកោម្ហិ** ប្រែថា សត្វទាំងឡាយមានកម្មជារបស់ខ្លួន។ **កម្មទាយាទោ** សត្វទាំងឡាយមានកម្មជាមត៌ក។ **កម្មពន្ធុ** សត្វទាំងឡាយមានកម្មជាផៅពង្ស។ **កម្មយោនិ** សត្វទាំងឡាយមានកម្មជាកំណើត។ **កម្មប្បដិសរណា** សត្វទាំងឡាយមានកម្មជាទីនឹករលឹកឃើញ កសាងកម្មបែបណា តែងបានផលបែបនោះ។ អំពើបាបក្ដីអំពើបុណ្យក្ដីដែលបុគ្គលកសាង ទោះបីអ្នកដទៃដឹងក្ដីមិនដឹងក្ដីតែងតែឲ្យផលជាដរាប។

ពុទ្ធភាសិតមួយទៀតថា កម្មតែងចែកសត្វឲ្យថោកទាប និងខ្ពស់ខ្ពង់។ មួយទៀតថា **កម្មុនា វត្តតី លោកោ** ប្រែថា សត្វទាំងឡាយប្រព្រឹត្តទៅតាមអំពើរបស់ខ្លួន។ បានសេចក្តីថា មនុស្សសត្វបានសុខទុក្ខចំរើនវិនាសបែបណា ស្រេចតែអំពើ ឬការងាររបស់ខ្លួនជាអ្នករៀបចំ។ កម្មនេះ ជួនកាលលោក និយាយថា ហេតុគឺហេតុបែបណាតែងបញ្ចេញផលបែបនោះ ហេតុល្អបានផលល្អ ហេតុអាក្រក់បានផលអាក្រក់។ ជឿព្រះ ពុទ្ធសាសនា គឺជឿការពិតរបស់កម្មផលឬហេតុផលនេះឯង។ ក្នុងន័យនេះ ស្របនឹងពាក្យខ្មែរថា «ចេះមកពីរៀន មាន មកពីរក» គឺការរៀនការរកជាកម្មឬជាហេតុ ឯការចេះការមានជា ផល។ បើរៀនក្រចេះរកក្រមាន មកអំពីឧបនិស្ស័យតិចនិងខ្វះ បច្ចេកទេសក្នុងការរៀននិងការរក។ ត្រង់នេះ ស្របនឹងវិទ្យា សាស្រ្តគ្រប់ផ្នែកជាពិសេសផ្នែករូបវិទ្យានិងគីមីវិទ្យា គឺការផ្សំ ធាតុបែបណាតែងបង្កើតជាផលបែបនោះ។ ចលនារបស់ព្រះ អាទិត្យព្រះចន្ទផែនដីបង្កើតបានជារដូវត្រជាក់រដូវក្តៅជាដើម ស្រេចលើកម្មឬអំពើរបស់ផ្កាយទាំងនោះក្នុងលោកធាតុ។ ពាក្យ ថា កម្មនេះ ខ្មែរយើងមានលើកយកមកប្រើថា កសិកម្ម ការភ្ជួរ រាស់ដកស្ទូងដាំដុះ ឧស្សាហកម្ម ការផលិតដោយគ្រឿងម៉ាស៊ីន

ពាណិជ្ជកម្ម ការជួញដូរជាដើម។ សាសនាដទៃថា សេចក្តីសុខទុក្ខចំរើនវិនាសរបស់មនុស្សសត្វ ថាមកអំពីព្រះជាម្ចាស់ដែលមិនដឹងជានៅឯណាចាត់ចែងឲ្យ។ កម្មផលនិងហេតុផលនេះពុំមែនព្រះពុទ្ធជាអ្នកបង្កើតឡើងទេ គឺព្រះអង្គត្រាស់ដឹងការពិតនេះតាមច្បាប់ធម្មជាតិ (Natural law) ហើយត្រាស់សំដែងប្រាប់មនុស្សសត្វប៉ុណ្ណោះ។

ឈឈឈឈឈ

# ១០- ព្រះពុទ្ធដឹកនាំ
# អ្នកប្រតិបត្តិឲ្យចេញចាកទុក្ខ

ព្រះពុទ្ធជាមនុស្សជាតិ ទ្រង់ប្រសូតមានព្រះមាតាបិតាស្ថិតនៅលើផែនដី ហើយដែលនាំឲ្យព្រះអង្គមានលក្ខណៈប្លែកពីមនុស្សធម្មតានោះ គឺត្រង់ព្រះអង្គបានត្រាស់ជាព្រះពុទ្ធ ឃើញអរិយសច្ចជាធម៌ សំរាប់ចម្លងមនុស្សសត្វដែលប្រតិបត្តិតាមឲ្យចេញចាកទុក្ខ។ ព្រះអង្គត្រាស់ដឹងនូវលោកដែលហៅថា **លោកវិទូ** ប្រែថា ព្រះអង្គត្រាស់ដឹងនូវលោកបី គឺ**សង្ខារលោក** បានដល់ព្រះអាទិត្យ ព្រះចន្ទ ផែនដីជាដើម **សត្វលោក** បានដល់មនុស្សសត្វដែលមានចិត្តវិញ្ញាណ **ឱកាសលោក** បានដល់រចនាសម្ពន្ធរបស់លោកធាតុឬចក្រវាឡដែលមានចលនាទាក់ទងគ្នាតាមច្បាប់ធម្មជាតិនិងច្បាប់កម្មផល គ្មានអ្នកណាបង្កើតឡើយ។ ព្រះអង្គត្រាស់ដឹងនូវលោកធាតុឬចក្រវាឡទាំងអស់ តែព្រះអង្គពុំសំដែង ព្រោះពុំមានប្រយោជន៍ក្នុងការរំដោះទុក្ខមនុស្សសត្វ។ ព្រះអង្គសំដែងដោយយកហេតុបច្ច័យនៃលោកខាងក្រៅមកប្រៀបធៀបនឹងហេតុបច្ច័យនៃលោកក្នុងខ្លួនយើងថា លោកខាងក្រៅក៏ដូចជាលោកក្នុងខ្លួនយើងដែរ។

ព្រះពុទ្ធប្រោសមនុស្សសត្វដោយការសំដែងធម៌ទេសនា បង្ហាញហេតុផលឲ្យគេពិចារណា ហើយសម្រេចចិត្តជឿនិងប្រតិបត្តិតាមដោយខ្លួនគេ។ ពាក្យថា ព្រះពុទ្ធសំដែងធម៌ប្រោសមនុស្សសត្វដែលមានឧបនិស្ស័យដែលគួរទូន្មានបាន គឺមនុស្សសត្វដែលធ្លាប់ធ្វើទានរក្សាសីលចំរើនភាវនាពីមុនមក (**ទានូបនិស្ស័យ សីលូបនិស្ស័យ ភាវនូបនិស្ស័យ**) មនុស្សសត្វប្រភេទនេះ អាចទទួលធម៌ទេសនារបស់ព្រះអង្គយកទៅប្រតិបត្តិបាន។ រោគផ្លូវចិត្តរបស់មនុស្សសត្វបានដល់ លោភៈ ទោសៈ មោហៈ ជាឫសគល់អកុសល ដូច្នេះថ្នាំគឺ **ធម្មោសថ** ឱសថគឺព្រះធម៌ដែលត្រូវយកមកបំបាត់រោគទាំងនោះ បានដល់ទានសីលភាវនាហ្នឹងឯង។ ទានសីលភាវនានេះ សំរាប់ធ្វើឲ្យសង្គមមនុស្សរស់នៅជាមួយគ្នាបានសុខសាន្ត។ ដើម្បីឲ្យសង្គមមនុស្សស្រឡាញ់រាប់អានគ្នា ព្រះសម្ពុទ្ធបង្រៀនឲ្យមនុស្សធ្វើទាន ជួយសង្គ្រោះគ្នាដោយទ្រព្យសម្បត្តិ ដោយគំនិតបញ្ញា គឺជួយយិតយោងអ្នកទន់ខ្សោយឲ្យរស់នៅក្នុងសង្គមបានសុខស្រួលផង។ ដើម្បីកុំឲ្យមនុស្សនិងសង្គមមនុស្សបៀតបៀនគ្នា ព្រះពុទ្ធបង្រៀនឲ្យមនុស្សរក្សាសីល ដោយឲ្យផ្សាយមេត្តាចិត្តនិងករុណាចិត្តអាណិតអាសូរដល់គ្នាទៅវិញទៅមក។

ដើម្បីឲ្យមនុស្សនិងសង្គមមនុស្សទុកចិត្តគ្នា សាមគ្គីគ្នា ព្រះពុទ្ធបង្រៀនឲ្យមនុស្សអប់រំផ្លូវចិត្តឲ្យបានល្អ កុំលំអៀងព្រោះស្រឡាញ់ ព្រោះស្អប់ ព្រោះភ័យខ្លាច ព្រោះវង្វេងពុំដឹងការពិតឡើយ។ ខ្ពស់ពីនេះទៅទៀត ដើម្បីឲ្យផុតទុក្ខពីជាតិជរាព្យាធិមរណៈ ត្រូវប្រតិបត្តិតាមសីលសមធិបញ្ញាឬទានសីលភាវនានេះឲ្យបានម៉ត់ចត់បំផុត។ ព្រះពុទ្ធបានណែនាំថា អំពើអាក្រក់នាំឲ្យមានទុក្ខត្រូវលះបង់ អំពើល្អនាំឲ្យបានសុខត្រូវធ្វើឲ្យកើតច្រើនឡើង។ ហេតុផលអាក្រក់និងល្អនេះមាននៅក្នុងលោកជានិច្ច ព្រះពុទ្ធបានឃើញការពិតនេះយកមកសំដែងប្រាប់មនុស្សសត្វទាំងអស់គ្នា។ ក្នុងន័យនេះ បញ្ជាក់ថា ការពិតនៅតែជាការពិត ពុំមែនរឿងជឿឬពុំជឿឡើយ គឺធ្វើល្អបានល្អធ្វើអាក្រក់បានផលអាក្រក់ទៅតាមអំពើដែលខ្លួនបានប្រព្រឹត្ត។ ព្រះពុទ្ធជាអ្នកបង្ហាញផ្លូវ ចំណែកមនុស្សសត្វត្រូវដើរដោយខ្លួនឯង។ ធម៌របស់ព្រះពុទ្ធជាសច្ចធម៌មានតថភាពដែលមនុស្សគ្រប់រូបគ្រប់ជាតិសាសន៍អាចយកមកពិសោធន៍ឃើញការពិតដោយខ្លួនឯង(**បច្ចត្តំ វេទិតព្វោ**)។

ꕥꕥꕥꕥꕥ

# ១១- គុណមាតាបិតា ប្រៀបមកគុណព្រះពុទ្ធ

អ្នកកាន់ព្រះពុទ្ធសាសនាខ្លះចង់ដឹងថា **គុណមាតាបិតា** និង **គុណព្រះសម្មាសម្ពុទ្ធ** តើអង្គណាមានគុណច្រើនជាង? ជាដំបូងគប្បីយល់អំពីពាក្យថា**គុណ**។ ពាក្យ**គុណ** ជាភាសាបាលីដែលប្រែជាភាសាខ្មែរថា សេចក្តីល្អរបស់បុគ្គលណាម្នាក់។ ដូចពាក្យថា បុគ្គលនេះមានគុណធម៌ឬគុណសម្បត្តិល្អគួរសេពគប់។ ឧទាហរណ៍សាមញ្ញ ដូចបុគ្គលណាម្នាក់បានឲ្យវត្ថុអ្វីមួយដល់បុគ្គលណាម្នាក់ បុគ្គលដែលបានទទួលអំណោយពោលថា សូមអរគុណ។ គុណក្នុងទីនេះ សំដៅយកសេចក្តីល្អដែលបុគ្គលនោះលះវត្ថុធ្វើជាទាន។ ពាក្យគុណនេះមានលក្ខណៈស្មើគ្នានឹងពាក្យថាបុណ្យកុសលសុចរិតអំពើល្អ។

ចំពោះគុណដែលមាតាបិតាមានចំពោះកូនប្រុសស្រី គឺនៅត្រង់គាត់ចិញ្ចឹមបីបាច់រក្សាកូនប្រុសស្រីឲ្យរស់រានមានជីវិត បង្រៀនឲ្យចេះនិយាយស្តី បញ្ជូនកូនឲ្យទៅសិក្សារៀនសូត្រ អប់រំកូនឲ្យប្រព្រឹត្តអំពើល្អ ចែកមត៌កឲ្យកូនធ្វើជាដើមទុនសំរាប់រកស៊ីជាដើម។ ការបញ្ចេញជាសង្គហធម៌សង្គ្រោះនេះឡើង

ដោយសារមាតាបិតាមានទឹកចិត្តប្រកបដោយព្រហ្មវិហារធម៌ គឺ **មេត្តា ករុណា មុទិតា** និង**ឧបេក្ខា**។ គាត់មានទឹកចិត្តស្រឡាញ់រាប់អានកូនចាប់តាំងពីគាត់ដឹងថា កូនមកចាប់បដិសន្ធិហើយ។ គាត់មានចិត្តអាណិតអាសូរកូនពេលដែលកូនមានទុក្ខហើយខំប្រឹងដោះស្រាយ ដូចជាកូនមានជម្ងឺ ខំបន់ស្រន់ឲ្យកូនឆាប់ជា យកកូនទៅមន្ទីរពេទ្យព្យាបាលជម្ងឺ។ ពេលកូនមានសុខភាពល្អ បានសុខកាយសប្បាយចិត្ត ម្តាយឪពុកមានចិត្តសប្បាយរីករាយយ៉ាងក្រៃលែង។ ម្តាយឪពុកបានធូរស្រាលពីបន្ទុកខ្លួនដោយសារកូនធំពេញរូបពេញរាង ចេះទទួលខុសត្រូវក្នុងការរស់នៅរបស់ខ្លួនបានហើយ។ សកម្មភាពជាគុណធម៌ឬជាអំពើល្អរបស់គាត់មកលើបុត្រធីតាប្រុសស្រីនេះហើយ ដែលហៅថា**គុណ**។ គេមិនអាចបដិសេធថាគាត់គ្មានគុណឡើយ។ បើបដិសេធថាគាត់គ្មានគុណ ក៏ដូចជាបដិសេធអំពើល្អរបស់គាត់ធ្វើមកលើកូនប្រុសស្រីដូចពោលមកហើយដូច្នោះដែរ។ បើទទួលដឹងថា សកម្មភាពល្អរបស់គាត់មកលើកូនប្រុសស្រីមានពិតមែន នោះហើយជាការទទួលស្គាល់គុណរបស់គាត់ទាំងពីរ។ មានខ្លះពោលថា គាត់សប្បាយជាមួយគ្នាគាត់ក៏កើតយើងមកដូច្នេះគាត់គ្មានគុណអ្វីទេ។ ដូចបានពោលមកហើយ គុណនៅ

ត្រង់គាត់ចិញ្ចឹមកូនឲ្យរស់ បើគេសួរថាខ្លួនកើតមកពីណា មុខជាឆ្លើយថា ខ្ញុំកើតមកពីអ្នកនោះ ចុះអ្នកនោះធ្វើដូចម្ដេចទើបខ្លួនរស់ មុខជារកឃើញថា អ្នកដែលបង្កើតហើយចិញ្ចឹមខ្លួនឲ្យរស់នោះហើយ ជាអ្នកមានគុណ។ ត្រង់គាត់សប្បាយជាមួយគ្នា ឬគាត់មិនសប្បាយ ជារឿងផ្សេង មិនទាក់ទងនឹងការចិញ្ចឹមនេះឡើយ។ មួយទៀត មានពាហិរសាសនាគឺសាសនាដទៃក្រៅពីព្រះពុទ្ធសាសនាពោលថា ម្ដាយឪពុកគ្មានគុណលើកូនប្រុសស្រីទេ អ្នកដែលមានគុណ គឺព្រះអាទិទេពជាព្រះបង្កើតលោកវិញទេ។ នេះជាទស្សនៈគ្មានហេតុផល តើអ្នកណាបានឃើញព្រះបង្កើតលោក។ ព្រះពុទ្ធសាសនាសំដែងថា **អវិជ្ជា តណ្ហា ឧបាទាន** និង **កម្មផល** ជាតួសភាវធម៌ជាហេតុជាបច្ច័យនាំឲ្យកើតមនុស្សសត្វ។ ការកើតឡើងជាហេតុនាំឲ្យមានទុក្ខ ដូច្នេះដើម្បីបំបាត់ទុក្ខត្រូវលះបង់ឬសម្លាប់ហេតុដែលនាំឲ្យមានទុក្ខ គឺសម្លាប់អវិជ្ជានិងតណ្ហានេះឯង។ បើព្រះអាទិទេពបង្កើតមនុស្សសត្វ ដូច្នេះ ព្រះអាទិទេពជាមេបណ្ដាលឲ្យមនុស្សសត្វមានទុក្ខ តើត្រូវធ្វើដូចម្ដេចឲ្យមនុស្សសត្វអស់ទុក្ខ បើព្រះអាទិទេពគង់នៅ ព្រះអង្គនៅតែបង្កើតជាតិឲ្យមនុស្សសត្វមានទុក្ខតទៅទៀត មានជរាទុក្ខ មរណទុក្ខជាដើម? ចំណែកម្ដាយឪពុកពុំមែន

ជាហេតុបង្កើតជាតិដល់កូនឡើយ កូនមកចាប់បដិសន្ធិទៅតាមកម្មផលរបស់ខ្លួន ម្ដាយឪពុកគ្រាន់តែពផ្ទៃហើយចិញ្ចឹមកូនឲ្យរស់ប៉ុណ្ណោះ។ ការចិញ្ចឹមកូនឲ្យរស់នេះហើយ ដែលគាត់ជាអ្នកមានគុណ។

ចំណែកគុណរបស់ព្រះពុទ្ធ នៅក្នុងពុទ្ធគុណក្នុងព្រះនាមទាំង៩ មានព្រះនាមថា**អរហំ**ជាដើម ដោយសង្ខេបមានបី គឺ **វិសុទ្ធិគុណ បញ្ញាគុណ** និង **ករុណាគុណ**។ **វិសុទ្ធិគុណ** ប្រែថា សេចក្ដីបរិសុទ្ធ។ សេចក្ដីថា ព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេសគ្រឿងសៅហ្មងចិត្តអស់ហើយ។ ព្រះអង្គជាបុគ្គលបរិសុទ្ធ មិនធ្វើអំពើបាបគ្រប់យ៉ាងទាំងទីកំបាំងមុខទាំងចំពោះមុខ។ **បញ្ញាគុណ** ប្រែថាគុណគឺបញ្ញា។ សេចក្ដីថា ព្រះអង្គត្រាស់ដឹងនេះ ជាលោកុត្តរបញ្ញាជាបញ្ញាចេញចាកលោក ពុំមែនជាលោកិយបញ្ញាឡើយ។ **ករុណាគុណ** ប្រែថា គុណគឺករុណា។ ករុណា ប្រែថា ការអាណិតអាសូរមនុស្សសត្វរបស់ព្រះអង្គ ដែលកំពុងវិលកើតវិលស្លាប់ក្នុងសង្សារវដ្ដ។ ព្រះអង្គបានសំដែងព្រះធម៌ប្រោសសត្វ ឲ្យមនុស្សយកទៅប្រតិបត្តិតាម ដើម្បីឲ្យបានសម្រេចព្រះនិព្វានជាការរំលត់ទុក្ខ។

បើប្រៀបធៀបគុណមាតាបិតានិងគុណព្រះពុទ្ធមានលក្ខណៈខុសគ្នា។ វិសុទ្ធិគុណនិងបញ្ញាគុណជាសេចក្តីបរិសុទ្ធនិងបញ្ញាផ្ទាល់ខ្លួនព្រះអង្គ ចំណែកមាតាបិតាគុណនេះគ្មានទេ។ ករុណាគុណ ព្រះអង្គសំដែងធម៌ប្រោសមនុស្សសត្វឲ្យយកទៅប្រតិបត្តិតាមរហូតចេញចាកទុក្ខ ចំណែកមាតាបិតាជួយសង្គ្រោះកូនប្រុសស្រីឲ្យបានសុខស្រួលតែក្នុងជីវភាពបច្ចុប្បន្នប៉ុណ្ណោះ។ ដូច្នេះបញ្ជាក់ថា ព្រះពុទ្ធមានគុណពិសេសដ៏ខ្ពស់ខ្ពង់ជាងគុណមាតាបិតា។

# ១២- ករុណាត្រូវមានបញ្ញា

ព្រះពុទ្ធជាម្ចាស់បានបង្រៀនឲ្យមនុស្សសត្វមានករុណា អាណិតអាសូរ ហើយជួយសង្គ្រោះដល់អ្នកដែលមានទុក្ខ។ ត្រូវជៀសវាងគំនិតព្យាបាទ គឺធ្វើមិនឲ្យគេបានសុខ និងជៀសវាងគំនិតវិហឹង្សា គឺការបៀតបៀនធ្វើឲ្យគេមានទុក្ខ។ ប៉ុន្តែមានពុទ្ធភាសិតមួយបទពោលថា បុគ្គលបើឃើញប្រយោជន៍ខ្លួនហើយ ត្រូវធ្វើប្រយោជន៍ខ្លួនឲ្យសម្រេចជាមុន។ តួយ៉ាងដូចជាព្រះពុទ្ធព្រះបរមគ្រូ មុនព្រះអង្គសំដែងធម៌ទេសនាប្រោសសត្វ ព្រះអង្គកសាងខ្លួនព្រះអង្គឲ្យបានត្រាស់ជាព្រះពុទ្ធ ឲ្យដល់នូវទីបំផុតទុក្ខ ហើយមានសមត្ថភាពជាមុនសិន។ មួយទៀតទោះបីព្រះអង្គមានព្រះទ័យអាណិតអាសូរករុណាចិត្តចំពោះសព្វសត្វដែលមានទុក្ខយ៉ាងណាក៏ដោយ ក៏ព្រះអង្គពុំអាចប្រោសបានទាំងអស់គ្នាឡើយ គឺព្រះអង្គប្រោសបានចំពោះតែសត្វដែលមានឧបនិស្ស័យដែលគួរឲ្យព្រះអង្គប្រោសបានប៉ុណ្ណោះ។ ការសង្គ្រោះអ្នកដទៃ ត្រូវពិចារណាមើលកុំឲ្យការសង្គ្រោះនោះនាំឲ្យគ្រោះថ្នាក់ដល់ខ្លួន គឺករុណាត្រូវមានបញ្ញា បើមិនដូច្នេះទេ ការសង្គ្រោះខ្លះនឹងនាំឲ្យមានគ្រោះថ្នាក់ដល់ខ្លួន ដូចរឿងក្នុងគតិលោកដោយសង្ខេបតទៅនេះ។ មានបុរសម្នាក់

ចេះវិជ្ជាប្រោសមនុស្សសត្វដែលស្លាប់ឲ្យរស់ឡើងវិញ។ ថ្ងៃមួយ បុរសនោះទៅលេងព្រៃ បានឃើញសត្វខ្លាមួយដែលទើបស្លាប់ថ្មីៗ មានចិត្តអាណិតសត្វខ្លា ហើយចង់សាកល្បងវិជ្ជារបស់ខ្លួនផង ដោយខ្វះការពិចារណាអំពីគ្រោះថ្នាក់ដែលកើតឡើងដល់ខ្លួនពេលដែលសត្វខ្លារស់ឡើង។ បុរសនោះក៏តាំងរាយមន្តសូត្រប្រោសសពសត្វខ្លានោះឲ្យរស់ឡើងវិញដូចបំណង។ លុះសត្វខ្លានោះរស់ឡើងហើយ ក៏មានសេចក្ដីស្រេកឃ្លានចំណី ក៏ងាកចុះងាកឡើងមិនឃើញសត្វអ្វីដែលខ្លួនអាចចាប់យកជាចំណី ឃើញតែបុរសនោះនៅជិតខ្លួន ក៏ស្ទុះទៅទះកាច់កឱនត្របាក់ស៊ីមួយរំពេចដោយសេចក្ដីស្រេកឃ្លានរបស់ខ្លួន បុរសនោះក៏ដល់នូវមរណភាពទៅ។ បទកាកគតិថា «មាអើយមាណព ចេះសិល្បសាស្ត្រជប់ ជីវិតខ្លាបាន ធម្មតាខ្លាខ្លៅ ចិត្តខ្មៅសាមាន្យ មិនដឹងគេមាន គុណលើអាត្មា។ មានចិត្តសប្បុរស ទៅជប់ទៅប្រោស ឲ្យរស់រូបា ត្រឡប់ក្រញាំ ខាំក្បាលវិញណា នេះព្រោះអាត្មា មិនស្គាល់ពិសពាល។ បុរសនោះត្រូវស្លាប់ ដោយសារសប្បុរសខ្វះបញ្ញាពិចារណាអំពីគ្រោះថ្នាក់ដែលត្រូវកើតមានដល់ខ្លួនបន្ទាប់ពីសត្វខ្លាមានចង្ហូមរស់ឡើងវិញ។ ការគ្រាន់តែ

ចង់ពិសោធនូវវិជ្ជាសិល្បសាស្ត្ររបស់ខ្លួន អាចពិសោធទៅលើសត្វស្លូតបូតគ្មានចង្កូម។

រឿងនេះបានជាមេរៀនថា ធម៌មេត្តាករុណាត្រូវមានបញ្ញានៅជាមួយ។ បានសេចក្ដីថា ទោះបីមានចិត្តសប្បុរសយ៉ាងណាក៏ដោយ មុននឹងជួយសង្គ្រោះអ្នកដទៃ ចាំបាច់គេត្រូវតែពិចារណានូវលទ្ធផលបន្ទាប់ពីការសង្គ្រោះនោះ ព្រោះការសង្គ្រោះខ្លះឲ្យផលល្អដល់ខ្លួន ការសង្គ្រោះខ្លះឲ្យផលអាក្រក់ដល់ខ្លួនវិញ ដូចបុរសប្រោសសត្វខ្លាឲ្យរស់នេះឯង។ នៅប្រទេសឥណ្ឌាមានជនជាតិឥណ្ឌាម្នាក់គោរពពស់ ថ្ងៃមួយបានឃើញពស់មានពិសមួយដេកសម្ងំហាលភ្លៀងនៅកន្លែងមួយ ក៏មានចិត្តអាណិតក៏ចាប់យកមកដេកនៅក្នុងមុងជាមួយខ្លួន ក៏ត្រូវពស់ចឹកស្លាប់ក្នុងមុងនោះទៅ។ នេះជាជំនឿនិងសកម្មភាពល្ងង់ខ្លៅដែលធ្វើឲ្យអន្តរាយដល់ជីវិតខ្លួន។ នៅក្នុងធម្មបទនៃគម្ពីរព្រះពុទ្ធសាសនាមានដំណាលរឿង**នាងកុណ្ឌលកេសី**។ មានដំណាលរឿងយ៉ាងសង្ខេបថា នាងកុណ្ឌលកេសីជាកូនសេដ្ឋី ថ្ងៃមួយនាងស្ថិតនៅលើប្រាសាទក្រឡេកឃើញចោរម្នាក់ដែលគេបណ្ដើរយកទៅធ្វើទោស ក៏កើតចិត្តស្រឡាញ់ចោរនោះ ក៏ឲ្យគេយកប្រាក់ទៅលោះយកមកធ្វើប្ដី។ នៅជាមួយនាងមិនបានយូរ ដោយ

ចោរជាអ្នកគ្មានបុណ្យមករស់នៅជាមួយអ្នកមានបុណ្យគឺនាង កុណ្ឌលកេសី ចោរក៏កើតចិត្តអផ្សុកមានគំនិតគិតខុសថា បើអញបោកនាងនេះយកប្រាក់ទៅចាយវាយតែម្នាក់ឯងវិញ ប្រសើរជាង។ គិតយ៉ាងនេះហើយ ចោរក៏និយាយបញ្ឆោតនាងថា កាលខ្ញុំជាប់ទោស ខ្ញុំបានបន់ស្រន់អ្នកតានៅជើងភ្នំថា បើខ្ញុំបានរួចចាកទោសខ្ញុំនឹងទៅលាបំណន់ ឥឡូវនេះខ្ញុំបានរួចចាកទោសហើយ ខ្ញុំនឹងទៅលាបំណន់ សូមនាងស្លៀកពាក់ឲ្យស្អាតបាតពាក់មាសពេជ្រដែលមានតម្លៃឲ្យច្រើន ហើយយើងទាំងពីរនាក់ទៅលាបំណន់ជាមួយគ្នា ដោយមិនឲ្យមានអ្នកកំដរទៅជាមួយឡើយ។ នាងក៏ជឿចោរដោយមិននឹកគិតថា ចោរបញ្ឆោតឡើយ ក៏រៀបចំខ្លួនប្រាណតាមចោរបង្គាប់ ហើយធ្វើដំណើរទៅកន្លែងដែលចោរបង្ហាញប្រាប់។ លុះទៅដល់ហើយ ធ្វើឲ្យនាងស្រឡាំងកាំងដោយចោរបានប្រាប់នាងថា យើងនាំនាងមកទីនេះ ពុំមែនបន់ស្រន់អ្វីទេ គឺនាំនាងមកសម្លាប់។ នាងមានការភ័យតក់ស្លុតក៏និយាយទៅកាន់ចោរដោយក្តីរន្ធត់ថា តើអ្នកសម្លាប់ខ្ញុំតើបំណងអ្វី ចោរឆ្លើយថា ខ្ញុំចង់បានមាសពេជ្រដែលនាងពាក់មកនេះ ដើម្បីយកទៅតាមចាយវាយតាមបំណងយើង។ នាងនិយាយថា ក្រែងអ្នកជាប្តីខ្ញុំ អ្នកចង់បានអ្វីក៏អាច

យកបានតាមប្រាថ្នា ហេតុដូចម្ដេចបានជាសម្លាប់ខ្ញុំ នាងនិយាយបែបណាក៏ចោរស្ដាប់ពុំបានឡើយ។ ទើបនាងប្រមូលស្មារតីឲ្យរឹងមាំនៅចំពោះមុខគ្រោះថ្នាក់ដល់ជីវិតនេះ ត្រូវយកបញ្ញាមកប្រើពិចារណា ទើបឃើញល្បិចមួយដើម្បីសម្លាប់ចោរកំណាចនេះ។ គិតឃើញហើយ ទើបនាងនិយាយទៅកាន់ចោរដោយសំដីទន់ភ្លន់ថា មុននឹងអ្នកសម្លាប់ខ្ញុំ អនុញ្ញាតឲ្យខ្ញុំវាំសូមខមាទោសអ្នកជាមុនសិន ព្រោះនៅពេលដែលយើងទាំងពីរនាក់បានគ្នាជាប្ដីប្រពន្ធ ក្រែងខ្ញុំប្រព្រឹត្តឆ្គងទៅលើអ្នក សូមអ្នកអត់ទោសឲ្យខ្ញុំ កុំឲ្យខ្ញុំមានកម្មពៀរទៅអនាគតទៀត។ ចោរអស់លក្ខណ៍វាសីចុះបាបកម្មតាមឲ្យផល ក៏ជឿសំដីនាងឲ្យនាងធ្វើតាមបំណង។ នៅពេលដែលនាងវាំព័ទ្ធជុំវិញចោរនោះ គឺចោរអង្គុយលើផ្ទាំងថ្មក្បែរជ្រោះមួយ។ នៅពេលដែលនាងសំគាល់ឃើញថា ចោរកំពុងតែអង្គុយស្ដាប់នាងភ្លេចខ្លួនហើយ នាងក៏ខំប្រឹងច្រានចោរទម្លាក់ជ្រោះដោយដៃទាំងពីរយ៉ាងអស់ទំហឹង។ ចោរក៏ធ្លាក់ទៅក្នុងជ្រោះយ៉ាងជ្រៅទង្គិចនឹងថ្មស្លាប់ក្នុងពេលនោះទៅ។

រឿងនេះក៏ឲ្យមេរៀនថា ដំបូងនាងកុណ្ឌលកេសីគិតខុសស្មានតែចោរអាចលះបង់អំពើអាក្រក់របស់ខ្លួន មានចិត្តអាណិតឲ្យគេយកប្រាក់ទៅលោះឲ្យរួចចាកទោស រហូតដល់យកធ្វើជា

ប្ដីទៀតផង តែជនអកតញ្ញូនេះ មិនត្រឹមតែមិនដឹងគុណនាងទេ ថែមទាំងមានគំនិតសម្លាប់នាងទៀត។ ដូច្នេះហើយបានជាលោកពោលថា កុំជឿទុកចិត្តជនពាលដែលធ្លាប់ប្រព្រឹត្តអាក្រក់ ហើយមិនទាន់បានអប់រំតាមផ្លូវធម៌នៅឡើយ ក៏ដូចជាកុំទុកចិត្តសត្វមានចង្កូមមានខ្លាជាដើម។ ទីបំផុត នាងកុណ្ឌលកេសីបានគេចផុតពីសេចក្ដីស្លាប់ ដោយប្រើល្បិចសម្លាប់ចោរកំណាចនោះមុន។ ពេលនោះ អារុក្ខទេវតាដែលរក្សាព្រៃភ្នំនោះ បានឲ្យពរសព្ទសាធុការដល់នាងដែលប្រើបញ្ញាដោះស្រាយជីវិតខ្លួនឲ្យផុតពីស្លាប់បាន។ ដោយនឿយណាយក្នុងកាមលោកីយ៍ នាងកុណ្ឌលកេសីបានសុំអនុញ្ញាតពីព្រះពុទ្ធបួសជាភិក្ខុនី ហើយខំប្រតិបត្តិធម៌ ទីបំផុតបានសម្រេចជាព្រះអរហន្តកាត់កិលេសបានដោយដាច់ខាត ដល់នូវទីបំផុតទុក្ខក្នុងពេលនោះទៅ។

មានរឿងមួយទៀតដំណាលថា មានឥសីមួយអង្គឃើញឆ្មាកំពុងដេញចាប់កណ្ដុរមួយស៊ី លោកមានព្រះទ័យអាណិតក៏ជប់កណ្ដុរនោះឲ្យក្លាយជាឆ្មាដូចគ្នា ដើម្បីឲ្យគេចផុតពីឆ្មាចាប់ស៊ី។ ថ្ងៃក្រោយ មានឆ្កែមួយដេញចាប់ឆ្មាដែលពីដើមជាកណ្ដុរ ឥសីក៏ជប់ឲ្យទៅជាឆ្កែដូចគ្នា។ ថ្ងៃក្រោយមកទៀត មានខ្លាមួយដេញចាប់ឆ្កែស៊ីទៀត ឥសីក៏ជប់ឆ្កែឲ្យទៅជាខ្លាដូចគ្នា។ បន្ទាប់

ពីរួចគ្រោះថ្នាក់ ខ្លាដែលឥសីជប់នោះស្រេកឃ្លានចំណី ក៏ប៉ង លោតទៅសង្គ្រប់ចាប់ឥសីដែលជប់ខ្លួននោះស៊ីជាអាហារ។ ឥសីបានជ្រាបក៏គិតថា ឯងខំជួយសង្គ្រោះជីវិតវាជាច្រើនលើក ច្រើនគ្រា តាំងពីកំណើតវាជាសត្វកណ្តុររហូតជប់វាឲ្យទៅជា សត្វខ្លាដើម្បីឲ្យគេចផុតពីសេចក្តីស្លាប់ ឥឡូវនេះវាមិនត្រឹមតែ មិនដឹងគុណទេ ថែមទាំងចង់ស៊ីឯងជាចំណីទៀត ណ្ហើយជប់វា ឲ្យទៅជាសត្វកណ្តុរវិញទៅ។ បន្ទាប់ពីបានក្លាយខ្លួនជាកណ្តុរ វិញ ក៏នឹកអៀនខ្មាស រួចរត់ចូលព្រៃក្បែរនោះបាត់ទៅ។ មនុស្ស ដូចសត្វកណ្តុរនេះ ក៏មានខ្លះនៅក្នុងសង្គមមនុស្ស ពេលបានធ្វើ ធំមានបុណ្យមានយសសក្តិទ្រព្យសម្បត្តិ ភ្លេចកំណើតដើមរបស់ ខ្លួនដែលតូចទាបទន់ខ្សោយ ជាសត្វរមិលគុណ ក៏ដល់នូវសេច ក្តីវិនាសខ្លួននៅទីបំផុត។

ៜៜៜៜៜ

# ១៣- សីល៥របស់ព្រះពុទ្ធសាសនា

សីល៥ជាគោលសីលធម៌របស់មនុស្ស ដែលព្រះពុទ្ធបានបង្រៀនឲ្យមនុស្សទូទៅ ជាពិសេសឲ្យពុទ្ធបរិស័ទព្រះអង្គគោរពកាន់គ្រប់គ្នាអស់កាលជានិច្ច ហើយសីល៥នេះ ពុទ្ធបរិស័ទជាគ្រហស្ថតែងតែទទួលសមាទានពីព្រះសង្ឃបន្ទាប់ពីនមស្សការរួចរាល់ពេលធ្វើបុណ្យទានក្នុងព្រះពុទ្ធសាសនា។ សីលបានដល់ចេតនាល្អវៀរចាកសេចក្តីអាក្រក់តាមផ្លូវកាយនិងវាចា។ សីលមានន័យច្រើនយ៉ាងគឺ **សីលនំ** សីលមានន័យថាប្រក្រតីបានដល់ប្រក្រតីខាងល្អ គឺប្រព្រឹត្តល្អជាប្រក្រតី; **សិរដ្ឋោ** សីលមានន័យថាជាកំពូល គឺបើមានសីលហើយ កុសលដទៃទៀតរមែងកើតមាន; **សីសដ្ឋោ** សីលមានន័យជាប្រធាន គឺបើមានសីលជាប្រធានដឹកនាំហើយ កុសលដទៃទៀតរមែងកើតមាន; **សីតលដ្ឋោ** សីលមានន័យថាត្រជាក់ គឺបុគ្គលមានសីលរមែងមានចិត្តត្រជាក់មិនក្តៅក្រហាយស្តាយក្រោយដោយខ្លួនមិនមានកំហុស។

សីល៥មានសិក្ខាបទ៥ គឺ៖

**១. បាណាតិបាតា វេរមណី** ហាមមិនឲ្យសម្លាប់គ្នា គឺហាមមិនឲ្យសម្លាប់ជីវិតមនុស្សសត្វទូទៅដែលមានជីវិតសញ្ញា ស្រឡាញ់ជីវិតចង់រស់មិនចង់ស្លាប់ មានការភ័យតក់ស្លុតចំពោះអាជ្ញាការគំរាមកំហែងគ្រប់យ៉ាង។ ការដែលព្រះពុទ្ធហាមមិនឲ្យសម្លាប់គឺជាការគោរពជីវិតអ្នកដទៃ ការសម្លាប់ឈ្មោះថា រំលោភលើជីវិតអ្នកដទៃ ព្រោះមនុស្សសត្វគ្រប់រូបមានសិទ្ធិរស់នៅដូចគ្នា។ ផ្លូវអាណាចក្រ គេបង្កើតច្បាប់បង្កើតប៉ូលីសដើម្បីការពារសន្តិសុខជូនប្រជាពលរដ្ឋ កុំឲ្យមានការសម្លាប់គ្នា។ ដូច្នេះ បើមនុស្សទាំងអស់កាន់សិក្ខាបទទី១នេះរបស់ព្រះពុទ្ធ គឺមិនសម្លាប់គ្នា ពិតជាជួយសម្រួលដល់ផ្លូវអាណាចក្រ មិនចំណាយប្រាក់កាសបង្កើតប៉ូលិសដើម្បីបង្ក្រាបអ្នកសម្លាប់ឡើយ។

**២. អទិន្នាទានា វេរមណី** ហាមមិនឲ្យកាន់យកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យដោយកាយឬដោយវាចាដោយចេតនាលួច។ ការហាមមិនឲ្យលួច គឺជាការគោរពកម្មសិទ្ធិទ្រព្យសម្បត្តិអ្នកដទៃដោយត្រូវគិតថា ខ្លួនស្រឡាញ់ទ្រព្យសម្បត្តិរបស់ខ្លួនមិនចង់ឲ្យបាត់បង់យ៉ាងណា អ្នកដទៃក៏មានចិត្តបែបនេះដូចគ្នា។ ផ្លូវអាណាចក្រ រដ្ឋបានចំណាយថវិកាជា

ច្រើនក្នុងការបង្ក្រាប ចោរលួច ចោរប្លន់ ចោរឆក់ ការកេងប្រវញ្ចន៍គ្នាគ្រប់បែបយ៉ាង។ បើចោរជាប្រជាជនធម្មតា ស្រណុកបង្ក្រាប ប៉ុន្តែបើអ្នករដ្ឋការស៊ីសំណូកពុករលួយ ពិបាកបង្ក្រាបណាស់។ ដូច្នេះ បើគេកាន់សិក្ខាបទទី២ កុំលួចកុំប្លន់ បញ្ហាដូចពោលមកនេះពុំកើតមានឡើយ ជាការជួយសម្រួលដល់ផ្លូវអាណាចក្រមិនឲ្យមានការភ័យខ្លាចពីការបាត់បង់ទ្រព្យសម្បត្តិរបស់ខ្លួននិងរបស់ជាតិ ទៅណាមកណាមិនចាំបាច់ចាក់សោរផ្ទះឡើយ ព្រោះគ្មានចោរលួច។

**៣. កាមេសុ មិច្ឆាចារា វេរមណី** វៀរចាកការលួចប្រពន្ធកូនប្ដីអ្នកដទៃ គឺជាការគោរពកម្មសិទ្ធិនៃកូនប្រពន្ធនិងប្ដីរបស់អ្នកដទៃ។ មួយភាគធំនៃជម្លោះរហូតដល់កើតហឹង្សា គឺកើតមកពីការរំលោភផ្លូវភេទនេះឯង បើគេគោរពតាមសិក្ខាបទទី៣នេះ បញ្ហាព្យាបាទគ្នាដោយអំពើលួចសម្លាប់ ការជះទឹកអាស៊ីដដាក់គ្នានិងរោគអេដពុំកើតមានឡើយ។

**៤. មុសាវាទា វេរមណី** វៀរចាការពោលពាក្យកុហកពាក្យពុំពិត ព្រោះបើគេយកទៅធ្វើតាមនាំឲ្យខូចប្រយោជន៍គេ។ ការពោលពាក្យពុំពិត នាំឲ្យមនុស្សលែងទុកចិត្តគ្នា នាំឲ្យបែកសាមគ្គីគ្នា។ ចំពោះបញ្ហាជាតិ បើអ្នកដឹកនាំស្មោះត្រង់នឹងប្រជា

ពលរដ្ឋ ពោលពាក្យពិត ពុំភូតកុហកប្រជាពលរដ្ឋដែលមានលក្ខណៈធ្វើប្រជាភិថុតិ នោះសាមគ្គីជាតិនិងឯកភាពជាតិរមែងកើតមាន។

**៥. សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី** វៀរចាកការផឹកការជក់គ្រឿងស្រវឹងគ្រឿងញៀនគ្រប់ប្រភេទ។ បើប្រព្រឹត្តឲ្យកន្លងសិក្ខាបទទី៥នេះ មានទោស៦យ៉ាងគឺ ចំណាយថវិកាគ្រួសារលើសការចំណាយធម្មតា នាំបង្កើតជម្លោះ នាំឲ្យកើតរោគ ខូចកេរ្តិ៍ឈ្មោះ បង្ហាញកេរ្តិ៍ខ្មាស និងធ្វើឲ្យខ្សោយប្រាជ្ញាស្មារតី។

ដូចបានពោលមកហើយ គ្រាន់តែលើកយកសីល៥មកបង្ហាញប៉ុណ្ណោះ បញ្ជាក់ថាព្រះពុទ្ធសាសនាមានធម៌អប់រំមនុស្សក្នុងសង្គមឲ្យមានសុខសន្តិភាពរស់នៅជាមួយគ្នាប្រកបដោយសុខដុមរមនា។

## ១៤- ចរិយា៣យ៉ាងរបស់ព្រះពុទ្ធ

ព្រះពុទ្ធគ្រប់ព្រះអង្គតែងមានចរិយា៣យ៉ាងគឺ **ពុទ្ធត្ថចរិយា** ការប្រព្រឹត្តដើម្បីប្រយោជន៍ឲ្យបានត្រាស់ជាព្រះពុទ្ធ **ញាតត្ថចរិយា** ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់ព្រះញាតិ **លោកត្ថចរិយា** ការប្រព្រឹត្តដើម្បីជាប្រយោជន៍ដល់សត្វលោក។ ចរិយាទី១ជាប្រយោជន៍ផ្ទាល់ខ្លួនព្រះអង្គ ចរិយាទី២និងទី៣ជាប្រយោជន៍ព្រះញាតិនិងសត្វលោក គឺប្រយោជន៍អ្នកដទៃ។ តាមសេចក្តីពិត មុននឹងជួយអ្នកដទៃត្រូវតែជួយខ្លួនឯងជាមុនសិន។ ដូចជាជួយអ្នកដទៃដោយកម្លាំងកាយ ត្រូវតែខ្លួនឯងមានកម្លាំងកាយមាំមួនមានសុខភាពល្អ។ ជួយអ្នកដទៃដោយទ្រព្យសម្បត្តិត្រូវតែខ្លួនឯងមានទ្រព្យសម្បត្តិ។ ជួយអ្នកដទៃដោយចំណេះវិជ្ជាត្រូវតែខ្លួនឯងមានចំណេះចេះដឹង។ យ៉ាងណាមិញ ព្រះសម្ពុទ្ធដែលមានសមត្ថភាពអាចសំដែងធម៌ទេសនាប្រោសសត្វបានលុះត្រាតែព្រះអង្គបានត្រាស់ជាព្រះពុទ្ធជាមុនសិន។

១. **ចរិយាទីមួយនៃព្រះអង្គ** គឺការកសាងឲ្យបានត្រាស់ជាព្រះពុទ្ធ។ ព្រះអង្គបានតាំងព្រះទ័យជាអាទិភាព គឺការស្វែងរកព្រះធម៌ដើម្បីរំដោះខ្លួនព្រះអង្គឲ្យចេញចាកទុក្ខក្នុងវដ្តសង្សារ

គឺការកើតចាស់ឈឺស្លាប់។ គ្មានស្រឡាញ់អ្វីស្មើនឹងស្រឡាញ់ខ្លួនឡើយ បានជាព្រះពោធិសត្វខំកសាងបារមីធម៌មានទានបារមីជាដើម បានទទួលទុក្ខវេទនាអស់ពេលដ៏យូរជាច្រើនជាតិ។ បន្ទាប់ពីបានកសាងបារមីធម៌បរិបូរណ៌ហើយ នៅជាតិជាទីបំផុត ព្រះពោធិសត្វបានព្យាយាមពិសោធដោយវិធីគ្រប់បែបយ៉ាងដើម្បីស្វែងរកការពិតនេះ។ ដូចជាព្រះពោធិសត្វព្រះសិទ្ធត្ថ បន្ទាប់ពីបានបួសជាតាបសឥសីហើយ ព្រះអង្គបានសិក្សាពិសោធធ្វើសមាធិជាមួយគ្រូពីរនាក់ គឺអាឡារតាបសនិងឧទ្ទកតាបស ដែលមានឈ្មោះល្បីក្នុងសម័យនោះ។ បន្ទាប់ពីពិសោធពុំឃើញធម៌ត្រាស់ដឹង ទើបព្រះអង្គលាអាចារ្យទាំងពីរហើយធ្វើការពិសោធដោយខ្លួនព្រះអង្គវិញ។ ព្រះអង្គធ្វើទុក្ករកិរិយា គឺជាអំពើដែលគេកម្រធ្វើកើត ដូចជាដកដង្ហើមតិចៗបន្ថយចង្ហាន់ជាដើម។ ដោយព្រះអង្គជ្រាបថាការប្រព្រឹត្តបែបនេះ ជាវិធីខុសមិនអាចត្រាស់ដឹងបាន ទើបព្រះអង្គលះបង់វិធីនេះចោលហើយប្រើបញ្ញាពិចារណាជាថ្មីទៀត។ លទ្ធផលនៃការពិសោធផ្សំនឹងបារមីធម៌ដែលព្រះអង្គកសាងពីជាតិមុនៗផង ព្រះអង្គបានរកឃើញផ្លូវត្រាស់ដឹង គឺមគ្គប្រកបដោយអង្គ៨ ហើយព្រះអង្គប្រតិបត្តិតាមផ្លូវនេះ ក៏បានត្រាស់ដឹងជាព្រះសម្មា

សម្ពុទ្ធ។ ដូច្នេះបញ្ជាក់ថា ការត្រាស់ដឹងជាព្រះពុទ្ធជាការក្រ គឺក្រនឹងបានត្រាស់ជាព្រះពុទ្ធ។ នៅពេលត្រាស់ដឹង ឈ្មោះថាព្រះអង្គបានរំដោះខ្លួនព្រះអង្គចេញចាកទុក្ខមានជាតិទុក្ខជាដើម ដោយដាច់ខាតហើយ។

២. **ចរិយាទីពីរនៃព្រះពុទ្ធ** គឺសង្គ្រោះព្រះញាតិ។ បន្ទាប់ពីត្រាស់ដឹងហើយ ព្រះអង្គបានយាងទៅប្រោសពុទ្ធមាតានិងបិតានិងព្រះញាតិវង្សដទៃទៀត ឲ្យត្រាស់ដឹងធម៌ហើយរួចចាកទុក្ខមានជាតិទុក្ខជាដើម ដោយការសំដែងធម៌ទេសនា។ កតញ្ញូការដឹងគុណជាធម៌របស់បណ្ឌិតដូចព្រះពុទ្ធព្រះបរមគ្រូជាដើម។ យ៉ាងណាមិញ ទំនាក់ទំនងរវាងព្រះមាតាព្រះបិតានិងព្រះញាតិវង្សដែលធ្លាប់មានគុណចំពោះព្រះអង្គកាលនៅជាគ្រហស្ថ ព្រះអង្គបានតបគុណនេះវិញដោយការពន្យល់ណែនាំប្រាប់មធ្យោបាយគឺព្រះធម៌ទៅរកការរំដោះទុក្ខ។ ព្រះសកម្មភាពនេះរបស់ព្រះពុទ្ធមិនឈ្មោះថាព្រះអង្គនិយមព្រះញាតិឡើយ តែជាភារកិច្ចចាំបាច់ដែលព្រះអង្គត្រូវបំពេញ ដែលជាអង្គរបស់បណ្ឌិត។

៣. **ចរិយាទីពរបស់ព្រះពុទ្ធ** គឺការសង្គ្រោះមនុស្សសត្វទូទៅ។ ទន្ទឹមគ្នានឹងការសង្គ្រោះព្រះញាតិ ព្រះអង្គបានប្រោសមនុស្សសត្វទូទៅដោយព្រះទ័យករុណាអាណិតអាសូរមនុស្ស

សត្វដែលកំពុងវិលកើតវិលស្លាប់ក្នុងវដ្តសង្សារ។ ត្រង់ពាក្យថា ព្រះអង្គទូន្មាននូវសត្វដែលមានឧបនិស្ស័យគួរនឹងទូន្មានបាន នោះ ក្នុងន័យថា សត្វនោះមានឧបនិស្ស័យគឺធ្លាប់បានធ្វើទាន សីលភាវនាពីមុនមក ទើបចាប់អារម្មណ៍ចំពោះព្រះអង្គទទួល យកធម៌ទេសនារបស់ព្រះអង្គទៅប្រតិបត្តិ។ បើសត្វនោះមិន ធ្លាប់ធ្វើល្អពីមុនមកទេ ពិបាកព្រះអង្គទូន្មានណាស់ មានសត្វខ្លះ មិនស្តាប់មិនជឿព្រះអង្គ ដោយពួកគេប្រកាន់ទិដ្ឋិមានជំនឿមួយ យ៉ាងមាំហើយ ត្រង់នេះហើយដែលពោលថា សត្វគ្មានឧបនិ ស្ស័យគួរឲ្យព្រះអង្គទូន្មានបានឡើយ។ សេចក្តីពិត ព្រះពុទ្ធ គ្រប់ព្រះអង្គតែងមានការអាណិតអាសូរចំពោះសត្វជាទូទៅមិន រើសមុខ ប៉ុន្តែលុះតែសត្វនោះចេះជួយខ្លួនឯងផងទើបព្រះអង្គ ប្រោសបាន។ ពាក្យថាសត្វដែលប្រើក្នុងទីនេះ គឺហៅបានចំ ពោះអ្នកដែលកើតក្នុងភពទាំងបី គឺអ្នកដែលជាប់ចិត្តក្នុងភព ដូចជាមនុស្សទេវតាព្រហ្មជាដើម ឯសត្វតិរច្ឆានក៏រាប់បញ្ចូល ក្នុងពាក្យនេះដែរ។ ប្រើពាក្យតែមួយ គឺព្រះពុទ្ធប្រោសសត្វ ហៅ បានអ្នកដែលទៅកើតក្នុងភពទាំងអស់។ មានតែព្រះនិព្វានទេ ដែលលែងឈ្មោះថាសត្វ ព្រោះព្រះនិព្វានរលត់តណ្ហាក្នុងភព ហើយ។ ដូចបានពោលមកហើយ ព្រះអង្គបានកសាងអស់

ពេលដ៏យូររហូតបានត្រាស់ជាព្រះពុទ្ធនេះ គឺបំណងប្រោសសត្វឲ្យចេញចាកទុក្ខ ចំណែកព្រះបច្ចេកពុទ្ធបានសម្រេចព្រះអរហន្តតែខ្លួនលោក ពុំមានសមត្ថភាពសំដែងធម៌ទេសនាប្រោសសត្វបានឡើយ។ ដោយសារការផ្សព្វផ្សាយធម៌ទេសនារបស់ព្រះអង្គនេះហើយ បានជាមនុស្សក្នុងលោករាប់រយលាននាក់បានទទួលកាន់ព្រះពុទ្ធសាសនា ហើយសព្វថ្ងៃនេះព្រះពុទ្ធសាសនាបានលូតលាស់យ៉ាងខ្លាំងនៅទ្វីបអឺរ៉ុបនិងនៅសហរដ្ឋអាមេរិក។

# ១៥- អធិបតេយ្យធម៌៣យ៉ាង

អធិបតេយ្យធម៌៣យ៉ាងគឺ **អត្តាធិបតេយ្យ** ការយកខ្លួនជាធំ, **លោកាធិបតេយ្យ** ការយកលោកជាធំ, និង**ធម្មាធិបតេយ្យ** ការយកធម៌ជាធំ, ទាំង៣នេះជាផ្នែកកុសល។ សេចក្តីថា ការយកធម៌ទាំងបីនេះ ធម៌ណាមួយមកធ្វើជាធំជាមូលដ្ឋាន នាំមិនឲ្យធ្វើអំពើបាប។

១. **អត្តាធិបតេយ្យ** ប្រែថា ការយកខ្លួនជាធំ គឺមិនហ៊ានប្រព្រឹត្តអាក្រក់ដោយយកខ្លួនឯងជាធំ ដែលមានលក្ខណៈនៃការពិចារណា៤បែបគឺ **១-ជាតិបច្ចវេក្ខិត្វា** ពុំហ៊ានប្រព្រឹត្តអាក្រក់ដោយពិចារណាជាតិត្រកូលពូជអម្បូរថា អាត្មាអញកើតមកមានជាតិត្រកូលពូជអម្បូរវង្សត្រកូលតាំងពីជីដូនជីតាមកធ្លាក់មានកេរ្តិ៍ឈ្មោះល្បីថា ជាត្រកូលមានពូជអម្បូរល្អត្រឹមត្រូវ បើអាត្មាអញប្រព្រឹត្តធ្វើអំពើអាក្រក់ទៅ ហាក់ដូចជាបន្ថោកតម្លៃនៃវង្សត្រកូលដែលធ្លាប់ប្រព្រឹត្តល្អពីដើមមក។ មួយទៀត ពិចារណាថា អាត្មាអញបានកើតមកជាមនុស្សនេះ ចាត់ជាមានកំណើតប្រសើរជាងកំណើតសត្វតិរច្ឆាន គួរប្រព្រឹត្តមនុស្សធម៌ មិនគួរប្រព្រឹត្តធ្វើអំពើថោកទាបដែលផ្ទុយអំពីកំណើតថ្លៃថ្នូរនេះ

ឡើយ។ កាលបើពិចារណាឃើញដូច្នេះ ក៏មិនហ៊ានធ្វើអំពើបាប។ **២-វយបច្ចវេក្ខិតា** ពិចារណានូវវ័យឬអាយុរបស់ខ្លួនថា អាត្មាអញមានវ័យកាន់តែចាស់ហើយ មិនគួរប្រព្រឹត្ត ធ្វើអំពើអាក្រក់ឡើយ។ ក្នុងវ័យនេះ គួរសន្សំសេចក្តីល្អ ព្រោះសេចក្តីស្លាប់កាន់តែមកជិតហើយ។ កាលបើពិចារណាឃើញដូច្នេះ ក៏លះបង់អំពើបាប។ **៣-សូរភាវំ បច្ចវេក្ខិត្វា** ពិចារណានូវសេចក្តីក្លៀវក្លានិងយសស័ក្តិរបស់ខ្លួនថា អាត្មាអញជាអ្នកដឹកនាំគេ មានយសស័ក្តិមានសេចក្តីក្លៀវក្លាគ្រប់ទីកន្លែង មានគេគោរពច្រើន គួរតែធ្វើចរិយាមារយាទឲ្យបានថ្លៃថ្នូរឲ្យបានល្អឡើងថែមទៀត។ បើអាត្មាអញ ជាអ្នកដឹកនាំគេ បែរទៅប្រព្រឹត្តធ្វើអំពើថោកទាប ធ្វើឲ្យគេមានទុក្ខទៅវិញ ឈ្មោះថាអាត្មាអញសម្លាប់ខ្លួនឯង គឺសម្លាប់កិត្តិយសរបស់ខ្លួនទៅវិញ ព្រោះថា បើចង់បានសុខខ្លួនឯងទៅបៀតបៀនអ្នកដទៃ ពុំបានសេចក្តីសុខឡើយ ឈ្មោះថាជាអ្នកស្អប់ខ្លួនឯងទៅវិញ ព្រោះបានប្រព្រឹត្តធ្វើហេតុដែលនាំឲ្យមានទុក្ខដល់ខ្លួន។ កាលបើពិចារណាដូច្នេះ ក៏វៀរចាកអំពើអាក្រក់ខ្មាសមិនហ៊ានធ្វើ។ **៤-ពាហុសច្ចំ បច្ចវេ-ក្ខិត្វា** ពិចារណានូវចំណេះចេះដឹងរបស់ខ្លួនថា អាត្មាអញបានរៀនសូត្រចេះដឹងច្រើន ជាអ្នកដឹងខុសដឹងត្រូវដឹងហេតុល្អហេតុ

អាក្រក់ គួរតែយកចំណេះចេះដឹងនេះមកជួយខ្លួនឯងនិងជួយសង្គ្រោះអ្នកដទៃ ជាពិសេសជួយប្រទេសរបស់ខ្លួន។ កាលបើពិចារណាដូច្នេះ ក៏មិនហ៊ានធ្វើអំពើបាប។

លក្ខណៈនៃការពិចារណាទាំង៤បែបនេះ ជា**អជ្ឈត្តិកសមុដ្ឋាន** ប្រែថាយកខ្លួនឯងជាសមុដ្ឋានក្នុងការពិចារណាមិនធ្វើអំពើបាប។ កន្លែងខ្លះហៅថា **ហិរិ** ប្រែថាខ្មាសអំពើបាបមិនហ៊ានប្រព្រឹត្តធ្វើ។

២. **លោកាធិបតេយ្យ** ប្រែថា យកលោកជាធំ គឺមិនហ៊ានធ្វើអំពើអាក្រក់ដោយយកសង្គមមនុស្សជាធំដែលមានលក្ខណៈនៃការពិចារណា៤បែបគឺ **១-ពុំហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់** ព្រោះខ្លាចខ្លួនឯងទិតៀនខ្លួនឯងបាន ហើយអំពើអាក្រក់នាំឲ្យខ្លួនមានវិប្បដិសារីក្តៅក្រហាយស្តាយក្រោយដោយសារតែកំហុសរបស់ខ្លួនដែលបានប្រព្រឹត្តកន្លងមកហើយ។ កាលបើពិចារណាដូច្នេះ ក៏បង្កើតស្មារតីប្រុងប្រយ័ត្នមិនឲ្យអំពើអាក្រក់កើតឡើងបាន។ **២-ពុំប្រព្រឹត្តធ្វើអំពើអាក្រក់** ព្រោះខ្លាចសង្គមមនុស្សជាពិសេសលោកអ្នកសប្បុរសរិះគន់ ទោះបីអំពើអាក្រក់ប្រព្រឹត្តធ្វើដោយគ្មានអ្នកណាដឹងក៏ដោយ។ **៣-ពុំហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់** ព្រោះខ្លាចមានទោសក្នុងបច្ចុប្បន្ន

ដូចជាគេចាប់ផ្ទើទោសធ្ងន់ស្រាលតាមកំហុសស្របតាមច្បាប់របស់រដ្ឋ។ **៤-មិនហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់** ព្រោះខ្លាចមានទោសក្នុងអនាគតជាតិ មានធ្លាក់ទៅសោយទុក្ខក្នុងនរកជាដើម។

លក្ខណៈនៃការពិចារណាទាំង៤បែបនេះ ជា**ពហិទ្ធាសមុដ្ឋាន** គឺយកអ្នកដទៃឬសង្គមមនុស្សខាងក្រៅខ្លួនឯងជាសមុដ្ឋានក្នុងការពិចារណាមិនធ្វើអំពើបាប។ កន្លែងខ្លះ ហៅថា **ឱត្តប្បៈ** គឺខ្លាចអំពើបាបមិនហ៊ានប្រព្រឹត្តធ្វើ។

**៣. ធម្មាធិបតេយ្យ** ប្រែថាយកធម៌ជាធំ គឺមិនហ៊ានប្រព្រឹត្តធ្វើអំពើអាក្រក់ដោយយកធម៌ជាធំ។ ធម៌ក្នុងទីនេះ សំដៅយកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធដែលជាតួពុទ្ធវចនៈ រួមដោយសេចក្តីសង្ខេបមាន៣យ៉ាង គឺការហាមមិនឲ្យធ្វើអំពើអាក្រក់ ឲ្យបំពេញសេចក្តីល្អ និងការជំរះចិត្តឲ្យស្អាតបរិសុទ្ធ ដោយពិចារណាថា ធម៌ដែលព្រះពុទ្ធសំដែងហើយ ជាសច្ចធម៌នាំមនុស្សសត្វដែលប្រតិបត្តិឲ្យចេញចាកទុក្ខ។ កាលបើមានជំនឿយ៉ាងមាំក្នុងព្រះធម៌នេះហើយ ទើបពុំប្រព្រឹត្តធ្វើនូវអំពើណាដែលខុសផ្លូវធម៌។ ធម្មាធិបតេយ្យ ជាច្បាប់ធម្មជាតិសាកលដែលរកឃើញដោយព្រះសម្មាសម្ពុទ្ធ ឯច្បាប់ផ្លូវលោកកើតឡើងពី

មនុស្សរបស់រដ្ឋនីមួយៗព្រមព្រៀងគ្នាបង្កើតឡើងសំរាប់សង្គមរៀងៗខ្លួន ពុំមែនជាច្បាប់មានការពិតសាកលឡើយ។ ច្បាប់ផ្លូវធម៌មានការពិតផង រំដោះទុក្ខមនុស្សសត្វផង ហើយនៅទីកន្លែងណានៅពេលវេលាណា ក៏អាចយកទៅអនុវត្តបាន។ ដូច្នេះ បើមនុស្សសត្វយកព្រះធម៌ជាធំ អនុវត្តតាមតែព្រះធម៌នោះ គេនឹងបានសេចក្តីសុខចំរើនក្នុងជីវភាពបច្ចុប្បន្ន ហើយនឹងបានសម្រេចព្រះនិព្វានរួចចាកទុក្ខមានជាតិទុក្ខជាដើមក្នុងអវសានជាតិ។

សូមកុំយល់ច្រឡំថា អត្តាធិបតេយ្យ បានដល់អត្តទត្ថភាព គឺការគិតតែប្រយោជន៍ផ្ទាល់ខ្លួន ឬយកតែគំនិតខ្លួនឯង មិនស្តាប់អ្នកដទៃ ជាគំនិតអត្តនោម័តិដូច្នេះឡើយ។ តាមពិត អត្តាធិបតេយ្យ ដែលប្រែថា យកខ្លួនជាធំនេះ ជាផ្នែកកុសលដោយពិចារណានូវខ្លួនមានលក្ខណៈ៤យ៉ាងដូចពោលមកហើយ មិនធ្វើអំពើបាបវិញទេ ពុំមែនមានន័យ មានះលើកដម្កើងខ្លួនឯងដូច្នេះឡើយ។ ឯពាក្យថា លោកាធិបតេយ្យដែលប្រែថាយកលោកជាធំនោះ ពុំមែនមានន័យថា សម្រេចអ្វីត្រូវយកតាមមតិភាគច្រើនតាមរបបប្រជាធិបតេយ្យដូច្នេះឡើយ។ លោកាធិបតេយ្យ មានន័យថា មិនធ្វើអំពើបាប ដោយខ្លាចខ្លួនឯងតិះដៀល

ខ្លួន ខ្លាចអ្នកដទៃរិះគន់ ខ្លាចច្បាប់រដ្ឋដាក់ទោស ខ្លាចធ្លាក់ទៅសោយទុក្ខក្នុងអបាយភូមិ៤មាននរកជាដើម ដូចបានពោលមកហើយវិញទេ។ បានសេចក្តីថា ពិចារណាអធិបតេយ្យធម៌ទាំងបី ឬអធិបតេយ្យណាមួយ ក៏អាចឲ្យបុគ្គលមិនធ្វើអំពើបាប គឺអធិបតេយ្យនេះមានលក្ខណៈល្អទាំងបីសំរាប់បុគ្គលពិចារណា មិនធ្វើអំពើបាប ពុំមែនដូចអ្នកខ្លះអធិប្បាយខុសអត្ថន័យនៃធម៌នេះកន្លងមកហើយទេ។

# ១៦- វាសនាបន្ទាប់ពីសេចក្ដីស្លាប់

អំពីវាសនាបន្ទាប់ពីសេចក្ដីស្លាប់នេះ មានទស្សនៈផ្សេងៗគ្នា ក្នុងទីនេះ សូមលើកយកតែទស្សនៈពីរមកអធិប្បាយ បន្ទាប់មក សូមលើកយកញាណទស្សនវិជ្ជារបស់ព្រះពុទ្ធសាសនាមកអធិប្បាយពន្យល់អំពីការពិតនៃវាសនាបន្ទាប់អំពីសេចក្ដីស្លាប់នេះ។

**សស្សតទិដ្ឋិ** ជាទស្សនៈមួយដែលយល់ថា សត្វស្លាប់ទៅធ្លាប់កើតជាយ៉ាងណានៅតែកើតយ៉ាងនោះ ដូចជាធ្លាប់កើតមកជាមនុស្សស្លាប់ទៅក៏នៅតែកើតមកជាមនុស្សដដែល។ទស្សនៈនេះ កើតចេញពីសាសនាព្រាហ្មណ៍ ដែលយល់ថារូបរាងកាយស្លាប់ទៅ ចំណែកចិត្តវិញ្ញាណឬអាត្ម័នតាមភាសាសំស្ក្រឹត អត្តាជាភាសាបាលី ព្រលឹងជាភាសាខ្មែរ ពុំស្លាប់ទេចេញពីរូបរាងកាយទៅកើតទៀត ប្រៀបដូចផ្ទះដែលត្រូវភ្លើងឆេះ អ្នកម្ចាស់ផ្ទះតែងតែទៅកសាងផ្ទះថ្មីទៀតជាធម្មតា។ នេះជាទស្សនៈយល់ថា ចិត្តទៀងមិនស្លាប់ទៅតាមរូបរាងកាយឡើយ។ ព្រះពុទ្ធបានបដិសេធនូវទស្សនៈនេះ ដោយព្រះអង្គបញ្ជាក់ថាបន្ទាប់ពីស្លាប់ទៅ ចិត្តវិញ្ញាណក៏រលត់ទៅជាមួយនឹងរូបដែរ

ព្រោះចិត្តវិញ្ញាណកើតមានដោយហេតុបច្ច័យអាយតនៈខាងក្នុងនិងខាងក្រៅប៉ះគ្នា ទើបកើតវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម។

**ឧច្ឆេទទិដ្ឋិ** ជាទស្សនៈមួយដែលយល់ថា សត្វស្លាប់ទៅសូន្យពុំកើតទៀត ប្រៀបដូចពួករុក្ខជាតិទាំងឡាយ បើវាងាប់ទៅគ្មានបន្តកំណើតទៀតទេ។ ទស្សនៈនេះ ច្រើនចេញមកពីក្រុមវិទ្យាសាស្ត្រខាងសម្ភារនិយម។ ទស្សនៈនេះ ព្រះពុទ្ធបានច្រានចោលទៀត ដោយព្រះអង្គលើកយកហេតុបច្ច័យ គឺបើនៅមានអវិជ្ជាតណ្ហាឧបាទាននិងកម្ម វានឹងមានជាវិបាកតទៅទៀត។

## ញាណទស្សនវិជ្ជារបស់ព្រះពុទ្ធសាសនា

នៅក្នុងគម្ពីរសុត្តន្តបិដកពុំនិយាយថា សត្វស្លាប់ទៅកើតទៀតឬពុំកើតទៀតទេ តែព្រះពុទ្ធលើកយកមូលដ្ឋានមួយសំខាន់ថា កើតទៀតឬមិនកើតទៀតនោះ វាអាស្រ័យទៅលើហេតុបច្ច័យ បើមនុស្សសត្វណានៅមានអវិជ្ជា តណ្ហា ឧបាទាន កម្ម សត្វនោះនៅបន្តកំណើតតទៅទៀត បើអស់ហេតុបច្ច័យទាំងនេះហើយ នឹងឈប់បន្តកំណើតតទៅទៀត បានដល់ព្រះអរហន្ត។ នៅក្នុងបដិច្ចសមុប្បាទធម៌ និយាយពីហេតុបច្ច័យ

បង្កើតជាផលបន្តគ្នា គឺអវិជ្ជានាំឲ្យមានសង្ខារ សង្ខារនាំឲ្យមានវិញ្ញាណ រហូតដល់មានជាតិនាំឲ្យមានជរានិងមរណៈ។ ដើម្បីយល់អំពីបដិសន្ធិ តើត្រូវបន្តរបៀបណានោះ គួរយល់អំពីខណៈចិត្តបច្ចុប្បន្ន គឺខណៈចិត្តដែលត្រូវបន្តទៅភពមួយទៀតក្រោយពេលមរណភាព ពុំខុសគ្នាពីខណៈចិត្តដែលកើតរលត់ក្នុងបច្ចុប្បន្ននេះទេ។ គ្មានចិត្តពីកំណើតដែលស្ថិតនៅជានិច្ចឡើយ គឺចិត្តវិញ្ញាណដែលអាចកើតឡើង ក៏ដោយអាស្រ័យភ្នែកត្រចៀកច្រមុះអណ្តាតកាយនិងមនោ ប៉ះអារម្មណ៍ខាងក្រៅ គឺរូបសម្លេងក្លិនរសសម្ផស្សនិងធម្មា (អ្វីមួយដែលចិត្តតោងមកជាអារម្មណ៍) ទើបកើតចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជីវ្ហាវិញ្ញាណ កាយវិញ្ញាណ និងមនោវិញ្ញាណ។ ចុះបើអាយតនៈខាងក្នុងទាំង៦ដែលស្ថិតនៅក្នុងកាយដែលជាប្រដាប់បង្កើត វិញ្ញាណបានត្រូវស្លាប់ តើមានវិញ្ញាណឯណាដែលសល់នៅចេញទៅកើតទៀត។ ចិត្តវិញ្ញាណនេះ សូម្បីជីវិតរស់នៅក្នុងបច្ចុប្បន្ន ក៏តែងតែកើតរលត់ជានិច្ចទៅតាមអារម្មណ៍ផ្សេងៗ។ មនុស្សស្លាប់គឺការអស់ដង្ហើមចេញចូលអស់ភ្លើងធាតុ អស់វិញ្ញាណ គឺលែងដឹងខ្លួន គឺរលាយទាំងរូបរលត់ទាំងនាម (វេទនា សញ្ញា សង្ខារ វិញ្ញាណ)។

បើវិញ្ញាណក្នុងខន្ធ៥នេះមិនទៅកើតទៀតទេ តើអ្វីទៅកើតទៀត? គម្ពីរអភិធម្ម បញ្ជាក់ថា ទោះបីខន្ធ៥បានត្រូវស្លាប់ ប៉ុន្តែកម្មដែលខន្ធចាស់បានកសាងបានក្លាយជាវិបាកសំរាប់បដិសន្ធិទៅភពខាងមុខទៀត។ បើជាកាមាវចរសត្វមានមនុស្សជាដើម មុននឹងស្លាប់ ជវនចិត្តបានតោងយកនិមិត្តបីនិមិត្តណាមួយ គឺ **កម្មៈ កម្មនិមិត្ត** និង **គតិនិមិត្ត**។ ខាងអំពើជាកុសលឃើញដូចខ្លួនកំពុងធ្វើទានរក្សាសីលនិងអប់រំចិត្ត បុគ្គលនោះស្លាប់ទៅនឹងទៅសោយសុខក្នុងសុគតិភព។ ខាងអំពើអកុសល ឃើញដូចខ្លួនកំពុងប្រព្រឹត្តអំពើអាក្រក់ផ្សេងៗមានសម្លាប់គេជាដើម បុគ្គលនោះស្លាប់ទៅ នឹងទៅសោយទុក្ខក្នុងទុគ្គតិភព។ បើបុគ្គលចំរើនឲ្យកើតជារូបាវចរជ្ឈាននិងអរូបាវចរជ្ឈាន បើឈាននោះមិនដាច់ទេ ស្លាប់ទៅនឹងកើតជាព្រហ្មមានរូបនិងព្រហ្មឥតរូប។ ចំណែកលោកុត្តរចិត្តដល់ថ្នាក់ព្រះអរហន្តមិនបន្តកំណើតជាថ្មីទៀតទេ។ **សម្មតិមរណៈ** ប្រែថាការស្លាប់ដោយសន្មត់ ព្រោះបន្តកំណើតតទៅទៀត។ ពាក្យថា **បដិសន្ធិ** មកពី **បដិ** ប្រែថា ឆ្ពោះទៅ **សន្ធិ** ប្រែថា ត ដូច្នេះពាក្យថា បដិសន្ធិ ប្រែថា បន្តជាតិឆ្ពោះទៅមុខទៀត។ **កម្ម** ជាធម្មជាតតាក់តែងភពជាតិឯវិបាកជាតួបដិសន្ធិ។ **ផលវិបាក** ប្រែថាវិបាករបស់ផល

គឺផលរួមគ្នាច្រើនបង្កើតបានជាវិបាកសំរាប់បដិសន្ធិទៅមុខទៀត។ ពាក្យខ្មែរថា មុននឹងដាច់ខ្យល់ស្លាប់ ចិត្តចាប់បដិសន្ធិមុន ប្រៀបដូចដង្កូវបាក់ខ្នង មុននឹងលែងជើងក្រោយវាតោងជើងមុខឲ្យជាប់សិន។ ប្រៀបនេះត្រូវ ប៉ុន្តែកុំយល់ច្រឡំដូចសាសនាព្រាហ្មណ៍ថាមានអាត្ម័នពុំចេះរលត់ឡើយ។ ក្នុងមិលិន្ទបញ្ហាគម្ពីរពុទ្ធសាសនាបានពន្យល់អំពីខន្ធចាស់ទាក់ទងទៅខន្ធថ្មី ដោយប្រៀបឧបមាដូចភ្លើងចង្កៀងដែលឆេះពីក្បាលព្រលប់រហូតដល់ភ្លឺ នឹងថាជាភ្លើងចាស់ពីក្បាលព្រលប់ក៏មិនមែនព្រោះវាឆេះដល់ភ្លឺហើយជាភ្លើងផ្សេង តែនឹងថាជាភ្លើងថ្មីសុទ្ធសាធក៏មិនមាន ព្រោះវាឆេះតពីភ្លើងក្បាលព្រលប់មក។ ត្រង់នេះបញ្ជាក់ថា ខន្ធថ្មីកើតមាន ព្រោះអាស្រ័យខន្ធចាស់ ដែលរុញច្រានដោយកម្លាំងកម្មឲ្យមានបដិសន្ធិតទៅទៀត។ ប្រៀបដូចបុគ្គលចោលដុំដី ដៃឈប់ហើយ តែចលនាដុំដីចេះតែមានចលនាទៅមុខទៀត ដូចកម្លាំងកម្មដែលបុគ្គលបានកសាងតែងមានថាមពលទៅតោងយកបដិសន្ធិ។ ប្រៀបដូចពន្លករុក្ខជាតិវាដុះអាស្រ័យគ្រាប់ចាស់ ឬប្រៀបដូចជាត្រានិងស្នាមរបស់ត្រាតួត្រាប្រៀបដូចជាកម្ម ឯស្នាមត្រាប្រៀបដូចជាតួវិបាកជាតួបដិសន្ធិ។ តាមវិទ្យាសាស្ត្រពោលថា ស្ត្រីអាចមានគភ៌ គឺស្ត្រី

ដែលមានស្បូនមានសុខភាពល្អ និងមានមេរូបញីនិងមេរូបឈ្មោលជួបគ្នា បណ្តើរគ្នាចូលទៅក្នុងស្បូន។ ព្រះពុទ្ធសាសនានិយាយដូច្នេះដែរ តែបន្ថែមកត្តាមួយទៀតលើសវិទ្យាសាស្ត្រ គឺសត្វបានចាប់បដិសន្ធិផង។ ចំណែក ព្រះអរហន្តទាំងឡាយមានព្រះពុទ្ធជាដើម រំលត់ខន្ធបរិនិព្វានហើយ គ្មានបន្តបដិសន្ធិជាថ្មីទៀតឡើយ ព្រោះព្រះអង្គបានកំចាត់បង់អវិជ្ជាតណ្ហាឧបាទាននិងកម្ម ដែលហេតុនាំឲ្យមានខន្ធ៥ចោលអស់ហើយ។

ᨱᨱᨱᨱᨱ

# ១៧- ទីស្ងាត់ពុំមានក្នុងលោក

ពុទ្ធភាសិតថា បុគ្គលមិនគប្បីធ្វើបាបក្នុងទីស្ងាត់ឡើយ ព្រោះទីស្ងាត់ពុំមានក្នុងលោកឡើយ។ ពាក្យថា ធ្វើបាបក្នុងទីស្ងាត់ក្នុងទីនេះ សំដៅយកការធ្វើបាបមិនឲ្យអ្នកណាដឹង គឺធ្វើអំពើណាមួយ ដែលទាក់ទងនឹងការប៉ះសិទ្ធិអ្នកដទៃ ក៏ខំបិទបាំងមិនឲ្យគេឃើញ ឬមិនឲ្យគេដឹងឮរឿងនោះ គឺលួចធ្វើ ឬប្រើល្បិចកិច្ចកលបង្វែងដាន មានពាក្យមួយហៅថា លាក់ការ។ តាមផ្លូវអាណាចក្រ ការប្រព្រឹត្តធ្វើអំពើអាក្រក់គ្រប់យ៉ាងរបស់មនុស្ស បើគ្មានគេដឹងឮ គ្មានគេឃើញជាសាក្សី គ្មានវត្ថុជាភ័ស្តុតាង ឬសាមីខ្លួនពុំទទួលសារភាពទេ តុលាការមិនអាចកាត់ឲ្យមានទោសឡើយ ព្រោះមិនមានភ័ស្តុតាង។ ចំណែកច្បាប់ផ្លូវធម៌ ឬច្បាប់ធម្មជាតិវិញ អ្នកប្រព្រឹត្តអំពើបាបរមែងសៅហ្មងចិត្តដោយខ្លួនឯងរួចទៅហើយ មិនសំខាន់នៅលើអ្នកដទៃដឹងឮឡើយ។ បើអ្នកដទៃពុំដឹងឮ ក៏អ្នកប្រព្រឹត្តធ្វើអំពើបាបរមែងក្តៅក្រហាយចិត្ត និងទទួលផលបាបក្នុងពេលណាមួយពុំខានឡើយ។ បាបនិងបុណ្យពុំមែនស្ថិតនៅលើការជឿឬមិនជឿឡើយ តែត្រូវស្ថិតនៅលើអំពើដែលគេធ្វើ បើគេធ្វើអំពើបែប

ណាតែងបានផលបែបនោះ ធ្វើបាបបានបាបធ្វើបុណ្យបានបុណ្យ។ នេះជាហេតុផលរបស់ច្បាប់ធម្មជាតិ ដែលមានចលនាកម្មនិងផលរបស់កម្មប្រព្រឹត្តទៅដោយខ្លួនឯងជាស្វ័យប្រវត្តិ។ អំពើគ្រប់យ៉ាងតែងមានផល ពុំមានអំពើណាមួយកើតឡើងដោយគ្មានផលនោះឡើយ។

ព្រះពុទ្ធប្រៀនប្រដៅមនុស្សសត្វ កុំឲ្យធ្វើអំពើបាប ទោះបីក្នុងទីកំបាំងក៏ដោយ ព្រោះអំពើបាប តែងតែផ្តល់ផលជាទុក្ខ។ ព្រះពុទ្ធមានព្រះនាមថា **អរហំ** ព្រោះព្រះអង្គឆ្ងាយចាកសឹកសត្រូវ ពោលគឺកិលេស ជាអ្នកមិនមានទីកំបាំង គឺព្រះអង្គមិនធ្វើបាបក្នុងទីកំបាំង ព្រោះឫសគល់ដែលនាំឲ្យសាងបាបកម្ម ព្រះអង្គបានលះបង់អស់ហើយ។ បើសង្គមមនុស្ស ជាពិសេសសង្គមខ្មែរនាំសិក្សានិងអនុវត្តតាមពាក្យប្រៀនប្រដៅនេះឲ្យបានម៉ត់ចត់ នឹងបានទទួលសេចក្តីសុខស្ងប់ពុំខានឡើយ ដោយសារមនុស្សមិនសាងអំពើបាបដោយការបៀតបៀនគ្នា។ អ្នកដែលធ្វើអំពើបាបដោយមិនដឹងថាបាបក្តី អ្នកដឹងហើយនៅតែប្រព្រឹត្តធ្វើក្តី តែងតែទទួលផលនៃបាប និងធ្វើឲ្យសង្គមមនុស្សទទួលគ្រោះថ្នាក់។ ព្រះពុទ្ធបានពន្យល់មនុស្សឲ្យឃើញទោសនៃអំពើបាប រហូតខ្លាចមិនហ៊ានធ្វើ។ បើពិចារណាមានកំរិត

ខ្ពស់ ដើម្បីបន្ថយបន្តិចម្តងៗនូវការមិនធ្វើអំពើបាប គឺពិចារណា នូវភាពមិនទៀងនៃអ្វីទាំងអស់ រួមទាំងខន្ធ៥របស់ខ្លួនផង។ របស់អ្វីមួយក្នុងលោកពុំមែននៅដដែលទេ វត្ថុមួយកើតមានក្នុងថ្ងៃនេះ ពុំមែនដូចរបស់ដែលកើតមានពីម្សិលមិញទេ ហើយក៏ពុំដូចជារបស់អ្វីមួយ ដែលនឹងកើតឡើងក្នុងថ្ងៃស្អែកដែរ នេះជាធម្មតានៃរបស់ដែលកើតឡើងក្នុងលោក ដែលជាអនិច្ចតាធម៌។

ព្រះពុទ្ធត្រាស់ដឹងធម៌ ឃើញអំពើបាបនិងបុណ្យ មានហេតុផលក្នុងខ្លួនរបស់វា ដែលមានលក្ខណៈផ្ទុយពីសាសនាដទៃ ដែលពោលថា បុណ្យបាបគុណទោសនិងរបស់អ្វីៗទាំងអស់ កើតឡើងពីព្រះអាទិទេព ពុំមែនកើតឡើងអំពីអំពើផ្ទាល់ខ្លួនទេ។ ការពោលនេះ ពុំអាចមានអ្វីបញ្ជាក់បានថាជាការពិតតាមលក្ខណៈវិទ្យាសាស្ត្រទេ។ ព្រះពុទ្ធសាសនាសំដែងថា អំពើប្រកបដោយចេតនាល្អអាក្រក់របស់មនុស្សសត្វនេះឯង ជាធម្មជាតិបែងចែកវាសនារបស់មនុស្សសត្វពុំមែនព្រះអាទិទេពទេ។ បើល្អអាក្រក់ស្ថិតនៅលើព្រះអាទិទេពពិតមែន យើងត្រូវតែឲ្យតម្លៃឬសរសើរគុណព្រះអាទិទេពចំពោះហេតុការណ៍ល្អកើតឡើង ប៉ុន្តែយើងត្រូវតែផ្តន្ទាទោសព្រះអាទិទេពចំពោះហេតុការណ៍អាក្រក់កើតឡើង នេះទើបយុត្តិធម៌ ព្រោះអ្វី? ព្រោះថា

បើមិនដាក់ទោសដល់ព្រះអាទិទេព ដែលធ្វើឲ្យមនុស្សលោកមានទុក្ខទេ នោះជាអំពើអយុត្តិធម៌ខ្លាំងណាស់មកលើមនុស្សមានទុក្ខ នោះជាអំពើអយុត្តិធម៌ខ្លាំងណាស់មកលើមនុស្សលោកដែលជាអ្នកទន់ខ្សោយ ហើយតើអ្នកណាប្រគល់អំណាចផ្តាច់ការនេះដល់ព្រះអង្គ? ពុទ្ធសាសនាពោលស្របតាមច្បាប់ផ្លូវអាណាចក្រសព្វថ្ងៃ គឺគេសរសើរគុណដល់មនុស្សណាដែលធ្វើត្រូវ ហើយគេផ្តន្ទាទោសដល់មនុស្សណាដែលធ្វើខុសរំលោភសិទ្ធិមនុស្ស។ ដូចបានពោលមកហើយនូវពុទ្ធភាសិតថា **បុគ្គលមិនគប្បីធ្វើបាបក្នុងទីស្ងាត់ឡើយ ព្រោះទីស្ងាត់មិនមានក្នុងលោកឡើយ** គឺព្រះពុទ្ធសំដែងអំពីចេតនាអាក្រក់ផ្លូវចិត្ត បើចិត្តមានចេតនាអាក្រក់ហើយ ត្រូវសៅហ្មងដោយខ្លួនឯង ហើយអំពើបាបកម្មគ្រប់យ៉ាងក៏កើតមានឡើងដោយសារចិត្តសៅហ្មង ហើយផលនៃអំពើបាបជាទុក្ខក៏កើតឡើង ខ្លួនឯងដឹងខ្លួនឯង មិនសំខាន់នៅលើអ្នកដទៃដឹងឬពុំដឹងឡើយ។

# ១៨- ការចូលព្រះវស្សារបស់ភិក្ខុសង្ឃ

រដូវវស្សាជារដូវភ្លៀង ព្រះភិក្ខុសង្ឃពិបាកធ្វើដំណើរពីកន្លែងមួយទៅកន្លែងមួយ ទើបព្រះពុទ្ធមានពុទ្ធាញ្ញាតឲ្យភិក្ខុសង្ឃនៅចាំព្រះវស្សានៅទីវត្តណាមួយដើម្បីរៀនសូត្រធម៌វិន័យនិងអប់រំចិត្ត ហើយងាយស្រួលឲ្យពុទ្ធបរិស័ទទំនុកបំរុងដោយបច្ច័យ៤ផង។ កន្លែងខ្លះនិយាយថា រដូវវស្សាជារដូវធ្វើស្រែចំការ ព្រះភិក្ខុសង្ឃនិមន្តចុះឡើងតែងតែជាន់សន្ទូងរបស់គេ ដោយមានការរិះគន់ពីអ្នកស្រែចំការ ទើបព្រះពុទ្ធមានពុទ្ធានុញ្ញាតឲ្យភិក្ខុសង្ឃចាំវស្សារហូតចប់រដូវភ្លៀង។ បើយកន័យនេះជាគោលការចាំព្រះវស្សាកន្លែងដទៃទៀត ដែលគ្មានធ្វើស្រែចំការ ពុំចាំបាច់ចូលវស្សាទេ។ ដូច្នេះ គួរសំអាងតាមគោលខាងដើមទើបសមរម្យជាង គឺរដូវភ្លៀងព្រះភិក្ខុសង្ឃពិបាកធ្វើដំណើររកបច្ច័យ៤មានការពិបាកក្នុងការនិមន្តបិណ្ឌបាត្រជាដើម ហើយបើនៅស្រុកស្រែចំការផង អ្នកស្រុកចេញទៅធ្វើការតាំងពីព្រលឹម ពុំអាចមានពេលដាក់បាត្រតាមពេលវេលាបាន ដូច្នេះបើព្រះសង្ឃចាំវស្សាមួយកន្លែង គេស្រណុកដាក់វេនគ្នាមួយក្រុមម្តងៗ ប្រគេនចង្ហាន់ចំពោះព្រះសង្ឃរហូតចេញព្រះវស្សា ព្រោះព្រះសង្ឃជំនាន់ពុទ្ធកាលពុំសូវគង់នៅមួយកន្លែង ច្រើនធ្វើដំណើរពីកន្លែង

មួយទៅកន្លែងមួយ។ បន្ទាប់ពីមានពុទ្ធានុញ្ញាតមក ការចូលព្រះវស្សាជាកិច្ចមួយចាំបាច់របស់ព្រះភិក្ខុសង្ឃរៀងរាល់ឆ្នាំ ហើយជាឱកាសឲ្យព្រះសង្ឃសិក្សារៀនសូត្រធម៌វិន័យនិងចំរើនសមថៈនិងវិបស្សនាផង។ ភិក្ខុសង្ឃត្រូវចាំវស្សានៅវត្តណាមួយចំនួន៣ខែ ចាប់តាំងពីថ្ងៃ១រោចខែអាសាឍ បើខែមានអធិកមាសគឺលើកខែ ត្រូវចូលនៅខែទុតិយាសាឍ។ ឯសាមណេរ ទោះបីគ្មានចែងក្នុងព្រះវិន័យថាឲ្យចាំវស្សា ក៏ត្រូវចូលវស្សាជាមួយព្រះភិក្ខុសង្ឃដែរ។ ចំណែក ឧបាសកឧបាសិកាជាគ្រហស្ថ ដែលមានសទ្ធាជ្រះថ្លាកាន់សីល៨ សីល១០ ឬធ្វើបាដិហារិយឧបោសថ ក៏អាចចូលវស្សាដំណាលគ្នានឹងភិក្ខុសង្ឃដែរ ដើម្បីបំពេញកិច្ចជាកុសលនេះ។ សូម្បីសត្វបក្សាបក្សីនិងសត្វល្អិតជំពូកខ្លះ នៅសម្ងំមួយកន្លែងនៅរដូវភ្លៀងដែរ ដោយវាសន្សំស្បៀងទុកជាមុន។

នៅយប់ថ្ងៃ១៥កើតខែបឋមាសាឍឬខែទុតិយាសាឍមុនចូលព្រះវស្សាមួយថ្ងៃ ពុទ្ធបរិស័ទបាននាំគ្នាទៅវត្តរួមអនុមោទនាជាមួយព្រះភិក្ខុសង្ឃដែលចូលព្រះវស្សា មានការហែទៀនព្រះវស្សា ស្តាប់ព្រះសង្ឃចំរើនព្រះបរិត្តនិងស្តាប់ទេសនា។ នៅស្រុកចំការដែលគ្មានភ្លើងអគ្គិសនី គេទិញប្រេងកាតប្រគេនព្រះ

សង្ឃទុកសំរាប់អុជបំភ្លឺក្នុងការសិក្សារៀនសូត្រនៅពេលយប់។ នៅពេលនេះគេប្រគេនគ្រឿងបរិក្ខារមានសំពត់សាដកឬសំពត់ងូតទឹកភ្លៀងជាដើម សំរាប់ទំនុកបំរុងព្រះសង្ឃក្នុងពេលចូលព្រះវស្សា។ លុះព្រឹកឡើងថ្ងៃ១រោច គេធ្វើពិធីរាប់បាត្រ វេរចង្ហាន់ប្រគេនព្រះសង្ឃ លុះដល់ពេលយប់នៃថ្ងៃដដែល ទើបព្រះភិក្ខុនិងសាមណេរសូត្រកំណត់ចូលព្រះវស្សា។

ក្នុងរយៈកាល៣ខែអំឡុងចូលព្រះវស្សានោះ វត្តខ្លះមានពុទ្ធបរិស័ទទៅសិក្សារៀនសូត្រព្រះពុទ្ធសាសនានិងអប់រំចិត្តដោយសមថៈនិងវិបស្សនាកម្មដ្ឋាន និងដាក់វេនចង្ហាន់ប្រគេនព្រះសង្ឃ។ ចំណែកព្រះសង្ឃក៏មានកម្មវិធីសិក្សាធម៌វិន័យនិងអប់រំចិត្តដែរ។ រយៈពេលចូលព្រះវស្សានោះ បើមានកិច្ចដូចជាទៅជួយរម្ងាប់អធិករណ៍របស់ភិក្ខុសង្ឃក្នុងវត្តណាមួយដែលបំរុងបែកគ្នា ទៅថ្វាយបង្គំព្រះឧបជ្ឈាយ៍ ទៅសួរសុខទុក្ខមាតាបិតាដែលជាញោម គេនិមន្តទៅទេសនា ទៅទទួលភត្តជាដើម ព្រះភិក្ខុសង្ឃអាចចេញពីវត្តបានចំនួន៧ថ្ងៃនិង៦រាត្រី ដោយត្រឡប់មកវត្តវិញឲ្យភ្លឺនៅវត្តដើមវិញនៅយប់ទី៧ ហៅថា លើក**សត្តាហៈ**។ ព្រះសង្ឃដែលបានចាំវស្សាគ្រប់ត្រៃមាសគឺគ្រប់៣ខែ អាចទទួលក្រាលគ្រងនិងអនុមោទនាកឋិនបាន ដោយអានិសង្ស

នៃការចូលវស្សានេះ។ ម៉្យាងទៀត ការចូលវស្សានេះមានប្រយោជន៍ជាពិសេសដល់ភិក្ខុសាមណេរក្នុងការសិក្សាពីគ្នាទៅវិញទៅមកនូវធម៌វិន័យ ហើយជួយរិះគន់គ្នាទៅវិញទៅមកក្នុងន័យស្ថាបនានូវទោសកំហុសខុសឆ្គងហើយកែលំអឲ្យត្រូវតាមធម៌វិន័យវិញ។

ប្រៀបមកផ្លូវអាណាចក្រវិញ គ្រួសារមួយឬសង្គមមួយដែលអាចរស់នៅជាមួយគ្នាបាន លុះត្រាតែស្ថិតនៅក្រោមអំណាចច្បាប់មួយ ដែលត្រូវគោរពទាំងអស់គ្នា បើមានការខុសឆ្គងបន្តិចបន្តួច គួរមានអធ្យាស្រ័យអត់ឱនឲ្យដល់គ្នាទៅវិញទៅមកប្រកបដោយមេត្តាធម៌ជារបៀបសុជីវធម៌។ តាមធម្មតាបើមានការរំលោភច្បាប់ប្រទេសដ៏ធ្ងន់ទើបធ្វើតាមកំហុស ក៏ដូចគ្នានឹងព្រះសង្ឃ បើមានកំហុសក្នុងព្រះវិន័យក៏ធ្វើតាមកំហុសដែរ។ ព្រះសង្ឃព្រះពុទ្ធសាសនារស់នៅជាមួយគ្នាបានសុខស្រួលដោយសារគោរពតាមព្រះវិន័យដែលព្រះពុទ្ធបានបញ្ញត្តិមក ជាពិសេសរស់នៅបានសុខស្រួលក្នុងរយៈកាល៣ខែក្នុងអំឡុងចូលព្រះវស្សានេះ។

ឡឡឡឡឡ

## ១៩- បុណ្យអុំទូក សំពះព្រះខែ បណ្តែតប្រទីប

**១. បុណ្យអុំទូក** គេធ្វើនៅថ្ងៃ១៥កើតខែកត្តិក ប៉ុន្តែគេធ្វើ ៣ថ្ងៃ គឺថ្ងៃ១៤,១៥កើតនិងថ្ងៃ១រោចខែកត្តិក។ ពិធីអុំទូកគេធ្វើនៅគ្រប់ទីកន្លែងពីជំនាន់ដើម ពិធីនេះច្រើនធ្វើរហូត៣ថ្ងៃ ប៉ុន្តែកន្លែងប្រារព្ធពិធីដ៏សំខាន់គឺនៅទន្លេចតុមុខនៃទីក្រុងភ្នំពេញ។ ជំនាន់ដើម ទូកដែលត្រូវប្រណាំងមាន៣០គូដែលបានជ្រើសរើសពីវត្តនានាក្នុងខេត្តទាំងឡាយនៃប្រទេសកម្ពុជាដែលនៅជិតមាត់ទន្លេ។ នៅពេលប្រណាំងមានភ្លេងពិណពាទ្យលេងនៅមុខដំណាក់ផែ។ នៅពេលល្ងាច ប្រជាពលរដ្ឋនិងអ្នករដ្ឋការបានមកជួបជុំគ្នារង់ចាំមើលការប្រណាំងទូកនោះ។ ចំណែកព្រះមហាក្សត្រក៏បានចូលរួមក្នុងពិធីនេះដែរ។ នៅពេលយប់មានអុជប្រទីបផ្ងាលានៅដំណាក់ផែនិងនៅតាមទូកកប៉ាល់នានា។ ជាមួយគ្នានេះ មានបណ្តែតប្រទីបដែលរចនាដោយរូបភាពក្បូរក្បាច់ផ្សេងៗចម្រុះដោយភ្លើងអគ្គិសនីគ្រប់ពណ៌ទៅតាមក្រសួងនិងសហគ្រាសនីមួយៗ។ ប្រទីបទាំងនោះបានរៀបចំនៅលើទូកកប៉ាល់តូចៗ ដែលត្រូវកប៉ាល់ធំៗសណ្តោងមកប្រជុំគ្នានៅទន្លេចតុមុខដំណាក់ផែ។ នៅវេលាពាក់កណ្តាល

អព្រាត្ររហូតដល់ភ្លឺ មានច្រៀងចម្រៀងសក្រវាទ៍ដោយក្រុមនារីកំដរដោយភ្លេងមហោរីពិណពាទ្យ។

២. **បុណ្យសំពះព្រះខែ** ហាក់ដូចជាទាក់ទងនឹងពុទ្ធសាសនាដោយធ្វើនៅថ្ងៃ១៥កើតខែកត្តិកនេះដែរ។ ដោយមានសេចក្តីដំណាលថា កាលព្រះពោធិសត្វយោងយកកំណើតកើតជាសត្វទន្សាយនៅថ្ងៃពេញបូណ៌មីបានក្រឡេកឃើញព្រះចន្ទពេញវង់ ក៏មានចិត្តជ្រះថ្លាចង់ដាក់ទានជីវិត។ ពេលនោះព្រះឥន្ទបាននិមិត្តធ្វើជាព្រាហ្មណ៍ចាស់ម្នាក់មកសុំសាច់ទន្សាយពោធិសត្វដើម្បីបំពេញទាន។ ពេលទន្សាយពោធិសត្វលោតចូលភ្លើងៗត្រូវរលត់អស់។ ឃើញហេតុអស្ចារ្យដូច្នេះ ឥន្ទព្រាហ្មណ៍ក៏ហោះទៅយកកែវមនោសិលា១ដុំទៅគូររូបទន្សាយក្នុងវង់ព្រះចន្ទនោះទៅ។ អាស្រ័យរឿងនេះបានជាអ្នកខ្លះពោលថា ឃើញដូចជារូបទន្សាយនៅក្នុងវង់ព្រះចន្ទ។ ការគោរពព្រះចន្ទឬសំពះព្រះខែក៏មានតមករហូតមកដល់សព្វថ្ងៃនេះ។ ការសំពះព្រះខែ កាលពីដើមគេធ្វើនៅសាក្យមុនីចេតិយ គឺគេធ្វើពីថ្ងៃ១៤ដល់១៥កើតខែកត្តិកជាថ្ងៃពេញបូណ៌មី។ គ្រឿងសក្ការបូជាគឺអំបុកចេកដូងសំរាប់ថ្វាយព្រះខែនិងថ្វាយព្រះរូបពោធិសត្វដែលស្ថិតនៅក្នុងវង់ព្រះចន្ទ។ ពេលជាមួយគ្នានោះ មាន

អុជទៀនធូបថ្វាយព្រះរតនត្រ័យនិងនឹកដល់ទេវតា។ តាមវត្តអារាមខ្លះនៅតាមខេត្តនិងជនបទក៏មានធ្វើពិធីនេះដែរ។ ការធ្វើបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែនេះ ជាពិធីទំនៀមទម្លាប់របស់ខ្មែរសំរាប់ចងភ្ជាប់ចិត្តគំនិតឲ្យសប្បាយរីករាយជាមួយគ្នា។

៣. **បុណ្យបណ្តែតប្រទីប** តាមទំនៀមធម្មតា អ្នកស្រុកនៅប្រទេសកម្ពុជាតែងធ្វើពិធីបុណ្យបណ្តែតប្រទីបនៅថ្ងៃបវារណាចេញព្រះវស្សារបស់ព្រះសង្ឃ ប៉ុន្តែនៅរាជធានី ព្រះមហាក្សត្រតែងប្រារព្ធធ្វើពិធីនេះរួមជាមួយពិធីអុំទូកសំពះព្រះខែនិងអកអំបុកដែលរាប់បញ្ចូលក្នុងពិធីទ្វាទសមាសនឹងរឿងនិទាន។ រឿងបុណ្យបណ្តែតប្រទីប ក្នុងគម្ពីរព្រះត្រៃបិដកនៃពុទ្ធសាសនាពុំឃើញមាននិយាយទេ ប៉ុន្តែមានឃើញក្នុងរឿងព្រេងខ្មែរ។ រឿងនោះមាននិយាយទាក់ទងនឹងពុទ្ធសាសនា។ មានសេចក្តីដំណាលថា នៅខាងដើមនៃភទ្ទកប្បយើងនេះ មានសត្វក្អែកសញ្ជីឈ្មោលបានបញ្ចេញពងបាន៥ តែពងទាំងនោះបានធ្លាក់ចុះក្នុងទឹកដោយខ្យល់ព្យុះ។ ក្អែកសញ្ជីញោលបានយំសោកបោកខ្លួនរហូតស្លាប់ដោយស្តាយពងរបស់ខ្លួន ហើយទៅកើតជាព្រះឥន្ទក្នុងស្ថានសួគ៌ទេវលោក។ ចំណែកពងទាំង៥

នោះ បានធ្លាក់នៅក្នុងកណ្ដាប់ដៃនៃសត្វទាំង៥គឺ មាន់ ស្ដេចនាគ អណ្ដើក គោនិងខ្លា បានរើសយកទៅចិញ្ចឹម ស្រាប់តែកើតមកសុទ្ធតែមនុស្សប្រុសទាំង៥។ កូនទាំង៥បានលាមាតាបិតាជាសត្វទៅសាងកុសលដើម្បីឲ្យបានត្រាស់ជាព្រះពុទ្ធរៀងៗខ្លួន។ សត្វទាំងនោះក៏បានអនុញ្ញាត ប៉ុន្តែបានធ្វើសំណូមពរថា បើកូនចេញទៅកសាងពុទ្ធភូមិបានត្រាស់ពេលណា សូមធ្វើឈ្មោះរបស់យើងឲ្យទៅជាប់នឹងឈ្មោះរបស់អ្នកផង។ រឿងនេះមានឈ្មោះដូចគ្នានឹងព្រះនាមព្រះពុទ្ធ៥ព្រះអង្គដែលបានត្រាស់ក្នុងភទ្ទកប្បនេះគឺ **កកុសន្ធោ** ប្រែថា មាន់, **កោនាគមនោ** ប្រែថា នាគ, **កស្សបោ** ប្រែថា អណ្ដើក, **គោតមោ** ប្រែថា គោ, និង **ព្រះសិរអារ្យមេត្តេយ្យ** ប្រែថា ខ្លា។ ថ្លែងពីមាណពទាំង៥បានជួបគ្នានៅកន្លែងមួយដោយមានគោលបំណងដូចគ្នាក៏សុំគ្នាធ្វើជាបងប្អូន ហើយជជែកគ្នារកមាតាបិតាដើម។ ក្អែកសញ្ជីឈ្មោលជាមាតាបិតាដែលបានកើតជាព្រះឥន្ទនិងព្រះអគ្គមហេសីនោះ ក៏ចុះមកដំណាលរឿងនេះប្រាប់ដល់មាណពទាំង៥ថា មាតាបិតាដើមរបស់អ្នកគឺយើងនេះឯង ដែលពីមុនគឺជាសត្វក្អែកសញ្ជីឈ្មោល។ ព្រះឥន្ទនិងអគ្គមហេសីបានផ្ដាំថា បើកូនរាល់គ្នានឹកអាល័យយើង ចង់បូជាអ្វី

ដល់យើងទាំងពីរនាក់ ចូរកូនគូសខ្វែងជើងក្អែកនៅគ្រប់វត្ថុដែលជាសំណែននោះហើយឧទ្ទិសដល់យើងទៅ។ មាណពទាំង៥បានបួសជាតាបស ហើយបានគូសជើងក្អែកនៅលើវត្ថុសំណែន សែនរួចក៏បណ្តែតតាមខ្សែទឹកហូរទៅ ដើម្បីបូជាក្អែកសញ្ញីឈ្មោលរហូតជាប់ជាទំនៀមមកដល់សព្វថ្ងៃនេះ។ តាមចាស់បូរាណពោលថា រឿងនេះដកស្រង់តាមរឿងសាស្ត្រាក្អែកសដែលជាសាស្ត្រាមានមកយូរហើយ ដូចគ្នានឹងគម្ពីររតនសង្គ្រោះនិងគម្ពីរពុទ្ធវង្ស។ ចំពោះរឿងបណ្តែតប្រទីបនេះតាមមតិអ្នកស្រុកខ្លះសំអាងថា គេធ្វើពិធីបណ្តែតប្រទីបនេះដើម្បីឧទ្ទិសបូជាចំពោះស្នាមព្រះពុទ្ធបាទនិងព្រះចង្កូមកែវដែលប្រតិស្ថាននៅនាពិភពនាគ។ ខ្លះថា ការបណ្តែតប្រទីបនេះ គឺឧទ្ទិសចំពោះព្រះចូឡាមណីចេតិយដែលស្ថិតនៅស្ថានត្រៃត្រឹង្ស។ ចំពោះរឿងក្អែកសញ្ញីឈ្មោលដែលថាជាមាតាបិតាដើមរបស់ព្រះពុទ្ធទាំង៥ព្រះអង្គក្នុងភទ្ទកប្បហើយថាជារឿងនាំឲ្យកើតការបណ្តែតប្រទីបដើម្បីឧទ្ទិសដល់សត្វក្អែកស ដែលចាត់ថាជារឿងមានហេតុអស្ចារ្យដែលពុំអាចជឿបានក៏ដោយក៏ចាត់ទុកជាវប្បធម៌ក្លាយជាប្រពៃណីរបស់ខ្មែរក្នុងការបណ្តែតប្រទីបនេះ។

បណ្ដាបុណ្យទាំង៣ប្រភេទនេះ បុណ្យអុំទូកមានប្រជាប្រិយ៍ជាងគេព្រោះមានសកម្មភាពរស់រវើក ហើយអ្នកមើលចាប់អារម្មណ៍ខ្លាំងត្រង់គេចង់ដឹងទូកណាឈ្នះទូកណាចាញ់។ ទូកដែលប្រណាំងគ្នានោះ លុះពេលក្រោយៗមកទៀត មានរាប់រយគូហើយគេឲ្យឈ្មោះទូកផ្សេងៗគ្នាទៅតាមក្រុមនីមួយៗ។ មុននឹងចាប់ប្រណាំង មានក្រុមទូកខ្លះ គេសំពះនឹករលឹកដល់គ្រូដើម្បីឲ្យទូកគេមានជ័យជំនះ។ ពេលប្រណាំងមានដូរ្យតន្ត្រីលេងកំដរលាយជាមួយអ្នកធ្វើអត្ថាធិប្បាយផង។ ទោះបីប្រវត្តិនៃពិធីបុណ្យទាំងបីនេះ មានរឿងទាក់ទងនឹងសាសនាព្រាហ្មណ៍ខ្លះក៏ដោយ ក៏ពិធីបុណ្យទាំងបីនេះក្លាយជាប្រពៃណីដ៏មានប្រជាប្រិយ៍របស់ប្រជាពលរដ្ឋខ្មែរទៅហើយ។ ពុទ្ធសាសនាគ្រាន់តែឲ្យយោបល់ថា អំពើគ្រប់យ៉ាងដែលមានប្រយោជន៍ គឺជាអំពើបណ្ដុះ **គុណធម៌** និង**សាមគ្គីធម៌**។

ᨐᨐᨐᨐᨐ